# ព្រះរាជាណាចក្រកម្ពុជា



កម្ពុជា

ផុន វិទ្យា និង

ជេនីហ្វើ ហ្វូលីហ្គែន

**ប្រអប់ព័ត៌មាន**[ii]

| | |
|---|---|
| ឈ្មោះប្រទេស | ព្រះរាជាណាចក្រកម្ពុជា |
| **រាជធានី** | ភ្នំពេញ |
| **ទទួលបានឯករាជ្យ** | ៩ វិច្ឆិកា ១៩៥៣ |
| **សាវតារប្រវត្តិសាស្ត្រ** | ព្រះមហាក្សត្រកម្ពុជាបានទទួលយកប្រទេសបារាំងជារដ្ឋអាណាព្យាបាលក្នុងឆ្នាំ ១៨៦៣ និងក្រោយពីសង្គ្រាមលោកលើកទី២បានបញ្ចប់ទៅក្នុងឆ្នាំ១៩៤៥ ចលនាដើម្បីឯករាជ្យបានចាប់ផ្តើមមានសន្ទុះឡើង។ ទីបំផុត ប្រទេសកម្ពុជាបានទទួលឯករាជ្យទាំងស្រុងពីប្រទេសបារាំងក្នុងឆ្នាំ ១៩៥៣។ ក្រោយពីសម័យអាណានិគម កម្ពុជាបានទទួលរងនូវការផ្លាស់ប្តូររបបជាច្រើន រួមមាន រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ (១៩៥៣-១៩៧០) របបសាធារណរដ្ឋ (១៩៧០-១៩៧៥) របបកុំម្មុយនីស្ត/ ផ្តាច់ការ (១៩៧៥-១៩៧៩) របបកុំម្មុយនីស្ត/សង្គមនិយម (១៩៧៩-១៩៨៩) និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញក្នុងឆ្នាំ ១៩៩៣។ នៅខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងបក្សកុំម្មុយនីស្តខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន។ យ៉ាងហោចណាស់ប្រជាជនកម្ពុជាជាង ១.៥លាននាក់បានបាត់បង់ជីវិតដោយសារ ការសម្លាប់រង្គាល ការបង្ខំធ្វើការហួសកម្លាំង ឬភាពអត់ឃ្លាន ចន្លោះពីឆ្នាំ ១៩៧៥-១៩៧៩។ នៅខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាម បានផ្តួលរំលំរបបនេះ ប៉ុន្តែកងកម្លាំងខ្មែរក្រហមនៅតែបន្តកាន់កាប់នូវមូលដ្ឋាន សំខាន់ៗនៅភាគពាយ័ព្យ[1]នៃប្រទេស។ សម្ថិផលនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បានធ្វើឲ្យកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជា និងបានកំណត់ការបោះឆ្នោតបែបប្រជាធិបតេយ្យ និងបទឈប់បាញ់គ្នា ប៉ុន្តែបក្សពួកខ្មែរក្រហមមិនបានគោរពដោយពេញលេញនោះទេ។ ការបោះឆ្នោតនៅឆ្នាំ១៩៩៣ គឺជាការគាំទ្រ និងផ្តល់ហរិញ្ញវត្ថុដោយអង្គការសហប្រជា-ជាតិ ដើម្បីជួយស្តារប្រទេសជាតិឡើងវិញ ក្រោមការដឹកនាំដោយរដ្ឋាភិបាលចម្រុះ។ ការវាយប្រហារទ្រង់ទ្រាយតូចកាលពីឆ្នាំ១៩៩៧ បានបញ្ចប់រដ្ឋាភិបាលចម្រុះទី១ ប៉ុន្តែការបោះឆ្នោតជាតិលើកទី២នៅឆ្នាំ១៩៩៨ បាននាំឆ្ពោះទៅរកការបង្កើតរដ្ឋាភិបាលចម្រុះថ្មីមួយ និងបង្កើតឡើងវិញនូវស្ថេរភាពនយោបាយ។ សមាសភាពខ្មែរក្រហម ដែលសេសសល់បានចុះចូលនៅដើម ឆ្នាំ១៩៩៩។ បណ្តាមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិត កំពុងតែរង់ចាំការកាត់ទោសលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយតុលាការកូនកាត់កម្ពុជា-អង្គការសហប្រជាជាតិ ក្រោមជំនួយគាំទ្រពីអន្តរជាតិ។ ការបោះឆ្នោតនៅ ខែកក្កដា ឆ្នាំ២០០៣ បានប្រព្រឹត្តទៅដោយសន្តិវិធី ប៉ុន្តែមានការចរចាររវាងគណបក្សនយោបាយប្រកួតប្រជែងរយៈពេលជាង១ឆ្នាំមុននឹងបានបង្កើតរដ្ឋាភិបាលចម្រុះ។ នៅខែតុលា ឆ្នាំ |

[1]កំណែចំពោះភាសាអង់គ្លេស: North-Eastern ទៅជា West-Eastern)

| | |
|---|---|
| | ២០០៤ ព្រះបាទ **នរោត្តមសីហនុ** បានដាក់រាជ្យ និងព្រះអង្គម្ចាស់ **នរោត្តមសីហមុនី** ត្រូវបានជ្រើសរើសឲ្យស្នងរាជ្យបន្តពីព្រះបីតា។ ការបោះឆ្នោតឃុំ-សង្កាត់បានប្រព្រឹត្តទៅនៅ ខែមេសា ឆ្នាំ២០០៧ ទោះបីជា មានអំពើហិង្សាតិចតួចមុនពេលបោះឆ្នោត។ ការបោះឆ្នោតជាតិនៅ ខែកក្កដា ឆ្នាំ២០០៨ បានប្រព្រឹត្តដោយសន្តិវិធី។ ចំណែកការបោះឆ្នោតជាតិជាបន្ទាប់ នឹងប្រព្រឹត្តទៅនាពាក់កណ្តាលឆ្នាំ ២០១៣។ |
| **ផ្ទៃដី** | 181,035 km2 |
| **ព្រំដែនដីគោក** | ឡាវ (541km) - ថៃ និងឈូងសមុទ្រថៃ (803km) - វៀតណាម (1,228km) |
| **ចំនួនប្រជាជន** | 14,453,680 (ប៉ាន់ប្រមាណក្នុងឆ្នាំ2010) អត្រាកើនឡើង 1.705% (ប៉ាន់ប្រមាណក្នុងឆ្នាំ2010) |
| **ប្រជាសាស្ត្រ** | អាយុ 0-14 : 32.6% (ប្រុស 2,388,922/ស្រី 2,336,439)<br>អាយុ 15-64 : 63.8% (ប្រុស 4,498,568/ស្រី 4,743,677)<br>អាយុ 65និងលើសពី 65 : 3.6% (ប្រុស 197,649/ស្រី 329,038) |
| **ទីក្រុង** | 20% នៃចំនួនប្រជាជនសរុប (ប៉ាន់ប្រមាណក្នុងឆ្នាំ2010) |
| **ភាសា** | ខ្មែរ (ផ្លូវការណ៍)95% - បារាំង - អង់គ្លេស |
| **សាសនា** | ព្រះពុទ្ធ 96.4% - មូស្លីម 2.1% - ផ្សេងៗ 1.3% - មិនច្បាស់លាស់ 0.2% (ជំរឿនឆ្នាំ1998) |
| **ការអប់រំ និង ការចេះអក្សរ** | អាយុ ១៥ឆ្នាំ អាចអាន និងសរសេរបាន:<br>76.3% នៃចំនួនប្រជាជនសរុប (ប៉ាន់ប្រមាណក្នុងឆ្នាំ2007) |
| **សុខុមាលភាព** | ចំនួនប្រជាជននៅក្រោមបន្ទាត់ភាពក្រីក្រ 31% (ប៉ាន់ប្រមាណក្នុងឆ្នាំ2007)<br>ប្រជាជន ១នាក់ ក្នុងចំណោម ៥នាក់ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ កង្វះអាហារ (2,100កាឡូរី/ថ្ងៃ) - ជីវិតរំពឹងរស់ 62.28ឆ្នាំ<br>របបសន្តិសុខសង្គមផ្តល់ឲ្យប្រជាពលរដ្ឋគ្រប់រូប - អ្នកក្រីក្រ - ជនពិការ -អតីតយុទ្ធជន និងកម្មករនិយោជិត (តាមបញ្ញាត្តិនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣)[2] |

[2]កំណែចំពោះភាសាអង់គ្លេស:បន្ថែមពាក្យក្នុងវង់ក្រចក"pursuant to provision of Cambodian Constitution 1993"

| | |
|---|---|
| ផលិតផលក្នុងស្រុកសរុប | $29.46 billion (ប៉ាន់ប្រមាណក្នុងឆ្នាំ2010) |
| ទិដ្ឋភាពទូទៅអំពីរដ្ឋាភិបាល | • ***ស្ថាប័ននីតិប្រតិបត្តិ*** ៖ ប្រមុខរដ្ឋ គឺ ព្រះបាទនរោត្តម **សីហមុនី** (តាំងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤) ដែលគ្រាន់តែជានិមិត្តរូប ចំណែកឯប្រមុខរដ្ឋាភិបាល គឺ (សម្តេចអគ្គមហាសេនាបតីតេជោ) នាយករដ្ឋមន្ត្រី **ហ៊ុន សែន** (តាំងពីថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៥) (ជាសហនាយករដ្ឋមន្ត្រីពីឆ្នាំ១៩៩៣ ដល់១៩៩៨[3])។ អំណាចនីតិប្រតិបត្តិបានប្រគល់ឲ្យខុទ្ទកាល័យ (ទីស្តីការគណៈរដ្ឋមន្ត្រី) ដែលត្រូវបានចាត់តាំងដោយនាយករដ្ឋមន្ត្រី និងតែងតាំងដោយព្រះមហាក្សត្រ ក្រោមការអនុម័តយល់ព្រមពីរដ្ឋសភា។ ក្រោយពីការបោះ ឆ្នោតឆ្នាំ២០០៨ មានការតែងតាំងឧបនាយករដ្ឋមន្ត្រីចំនួន ១០រូប។<br><br>• ***ស្ថាប័ននីតិប្បញ្ញត្តិ*** ៖ មានសភាពីរ គឺ ព្រឹទ្ធសភា (សមាជិក៦១រូប ៖ សមាជិក ២រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ - ២រូប ត្រូវបានបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា - និង ៥៧រូប ត្រូវបានបោះឆ្នោតជ្រើសតាំងដោយការបោះឆ្នោតអសកល[4] សមាជិកទាំងអស់មានអាណត្តិ៦ឆ្នាំ)[5] និងរដ្ឋសភា (សមាជិក ១២៣រូប ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ដែលមាន អាណត្តិ ៥ឆ្នាំ)។<br><br>• ***ស្ថាប័នតុលាការ*** ៖ អំណាចតុលាការ គឺគ្រប់គ្រងតុលាការគ្រប់ជាន់ថ្នាក់ និងជំនុំជម្រះគ្រប់រឿងក្តីរួមទាំង រឿងក្តីរដ្ឋបាល។ តុលាការត្រូវបានបែងចែកតាមឋានានុក្រម (គ្មានតុលាការពិសេស) រួមមានតុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង។ សាលាដំបូង មានតុលាការក្រុង តុលាការខេត្ត និងតុលាការយោធា។ រាជធានី និងខេត្តនីមួយៗ មានសាលាដំបូងមួយ លើកលែងតែក្រុងកែប ខេត្តឧត្តរមានជ័យ និងក្រុងប៉ៃលិន។ តុលាការយោធា ជំនុំជម្រះរឿងក្តីពាក់ព័ន្ធនឹងបទល្មើសវិន័យយោធា ដែលប្រព្រឹត្តដោយយោធិន ឬបទល្មើស ដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិយោធា។ សាលាដំបូងមានចំនួន ២១ សាលាឧទ្ធរណ៍មាន ០១ និងតុលាការ កំពូលមាន ០១។ ទោះបីជាយ៉ាងណា អំណាចក្នុងការពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់នានា មិនត្រូវបានប្រគល់ឲ្យស្ថាប័នតុលាការទេ ប៉ុន្តែតែអំណាចនេះត្រូវបានប្រគល់ឲ្យក្រុមប្រឹក្សាធម្មនុញ្ញ។ ឧត្តមក្រុមប្រឹក្សានៃ អង្គចៅក្រម (បានបង្កើតនិងមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧) គឺជាស្ថាប័នមួយដែលត្រួតពិនិត្យឯករាជភាព និងការតែងតាំង និងសម្រេចក្នុងការដាក់វិន័យលើចៅក្រម និងព្រះរាជអាជ្ញា។ |

[3]កំណែចំពោះភាសាអង់គ្លេស: ឆ្នាំ១៩៩៧ទៅជា១៩៩៨

[4]កំណែចំពោះភាសាអង់គ្លេស:ដោយកែ "សមាជិករដ្ឋសភានិងក្រុមប្រឹក្សាឃុំ-សង្កាត់"ទៅជា"ការបោះឆ្នោតអសកល"

[5]បន្ថែមកំណត់ចំណាំក្នុងជើងទំព័រ:ក្នុងអន្តរប្បញ្ញាត្តិនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាមាត្រា១៥៧ចែងថាអណត្តិព្រឹទ្ធសភាក្នុងនីតិកាលទី១គឺ៥ឆ្នាំហើយអណត្តិក្នុងនីតិកាលបន្ទាប់គឺ៦ឆ្នាំ (មើលមាត្រា១០០នៃរដ្ឋធម្មនុញ្ញ)។

| | |
|---|---|
| បញ្ហាសិទ្ធិមនុស្ស | សេរីភាពនៃការបញ្ចេញមតិ ការបង្កើតសមាគម និងកិច្ចប្រជុំនានា ការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងបញ្ហាដីធ្លី រួមទាំង សិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង (ការរឹបអូសដី និងការបណ្តេញចេញដោយបង្ខំ) តុលាការខ្វះឯករាជភាព និងការកើនឡើងនៃនិទណ្ឌភាព ការឃុំឃាំងដោយមិនត្រឹមត្រូវ និងការធ្វើទារុណកម្ម ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន (ការគំរាមកំហែងនៃការធ្វើមាតុភូមិនិវត្តន៍ដោយបង្ខិតបង្ខំ) |
| សមាជិកភាព ក្នុងអង្គការអន្តរជាតិ | ADB, ARF, ASEAN, CICA (observer), EAS,FAO,G77, IBRD, ICAO, ICC, ICRM, IDA, IFAD, IFC, IFRCS, ILO, IMF, IMO, Interpol, IOC, IOM, IPU, ISO (subscriber), ITU, MIGA, NAM, OIF, OPCW, PCA, UN, UNCTAD, UNESCO, UNIDO, UNIFIL, UNMIS, UNWTO, UPU, WCO, WFTU, WHO, WIPO, WMO, WTO |
| សន្ធិសញ្ញាសិទ្ធិមនុស្ស ដែល បាន ផ្តល់សច្ចាប័ន / យល់ព្រម/សម្រេច(ជ្រើសរើស) | • CERD : អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់រើសអើងពូជសាសន៍ (ថ្ងៃទី07 ខែមីនា ឆ្នាំ1966) (ចូលជាធរមាននៅថ្ងៃទី 04 ខែមករា ឆ្នាំ1969)<br>• CCPR : កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ថ្ងៃទី16 ខែធ្នូ ឆ្នាំ1966) (ចូលជាធរមាននៅថ្ងៃទី23 ខែមីនា ឆ្នាំ1976)<br>• CESCR : កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ថ្ងៃទី16 ខែធ្នូ ឆ្នាំ1966) (ចូលជាធរមាននៅថ្ងៃទី03 ខែមករា ឆ្នាំ1976)<br>• EDAW : អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ថ្ងៃទី18ខែធ្នូ ឆ្នាំ1979) (ចូលជាធរមាននៅថ្ងៃទី03 ខែកញ្ញា ឆ្នាំ1981)<br>• P-CEDAW : ពិធីសារបន្ថែមស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ថ្ងៃទី06 ខែតុលា ឆ្នាំ1999) (ចូលជាធរមាននៅថ្ងៃទី22 ខែធ្នូ ឆ្នាំ2000)<br>• AT : អនុសញ្ញាប្រឆាំងនឹងនឹងការធ្វើទារុណកម្ម និងភាពព្រៃផ្សៃផ្សេងទៀត ប្រព្រឹត្តកម្មបែបអមនុស្សធម៌ ឬថោកទាប ឬទណ្ឌកម្មផ្សេងៗ (ថ្ងៃទី10 ខែធ្នូ ឆ្នាំ1984) (ចូលជាធរមាននៅថ្ងៃទី26 ខែមិថុនា ឆ្នាំ1987)<br>• P-CAT: ពិធីសារបន្ថែមអនុសញ្ញាប្រឆាំងនឹងនឹងការធ្វើទារុណកម្ម និងភាពព្រៃផ្សៃផ្សេងទៀត ប្រព្រឹត្តកម្មបែបអមនុស្សធម៌ ឬថោកទាប ឬទណ្ឌកម្មផ្សេងៗ (ថ្ងៃទី18 ខែធ្នូ ឆ្នាំ2002) (ចូលជាធរមាននៅថ្ងៃទី22 ខែមិថុនា ឆ្នាំ2006)<br>• RC : អនុសញ្ញាស្តីពីសិទ្ធិនៃកុមារ និងការធ្វើវិសោធនកម្ម (ថ្ងៃទី20 ខែវិច្ឆិកា ឆ្នាំ1989) (ចូលជាធរមាននៅថ្ងៃទី02 ខែកញ្ញា ឆ្នាំ1990)<br>• P-CRC-AC : ពិធីសារជ្រើសរើសសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារអំពីការពាក់ព័ន្ធកុមារក្នុងជម្លោះ |

| | |
|---|---|
| | ប្រដាប់អាវុធ (ថ្ងៃទី25 ខែឧសភា ឆ្នាំ2000) (ចូលជាធរមាននៅថ្ងៃទី12 ខែកុម្ភៈ ឆ្នាំ2002)<br>•<br>P-CRC-SC ៖ ពិធីសារជ្រើសរើសសម្រាប់អនុសញ្ញាស្តីពីសិទ្ធិរបស់កុមារទាក់ទងនឹងការជួញដូរកុមារ ពេស្យាចារកុមារ និងអំពើអាសគ្រាមលើកុមារ (ថ្ងៃទី25 ខែឧសភា ឆ្នាំ2000) (ចូលជាធរមាននៅថ្ងៃទី18 ខែមករា ឆ្នាំ2002)<br>•<br>អនុសញ្ញាស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ថ្ងៃទី09 ខែធ្នូ ឆ្នាំ1948) (ចូលជាធរមាននៅថ្ងៃទី12 ខែមករា ឆ្នាំ1951) (ប្រទេសកម្ពុជាបានយល់ព្រមនៅ ថ្ងៃទី14 ខែតុលា ឆ្នាំ1950)<br>• អនុសញ្ញាទាក់ទងនឹងស្ថានភាពនៃជនភៀសខ្លួន (ថ្ងៃទី25 ខែកក្កដា ឆ្នាំ1951) (ចូលជាធរមាននៅថ្ងៃទី22 ខែមេសា ឆ្នាំ1954) (ប្រទេសកម្ពុជាបានយល់ព្រមនៅថ្ងៃទី15 ខែតុលា ឆ្នាំ1992)<br>• ពិធីសារជ្រើសរើសទាក់ទងនឹងស្ថានភាពនៃជនភៀសខ្លួន (ថ្ងៃទី31 ខែមករា ឆ្នាំ1967) (ចូលជាធរមាននៅថ្ងៃទី04 ខែមេសា ឆ្នាំ1957) (ប្រទេសកម្ពុជាបានយល់ព្រមនៅថ្ងៃទី12 ខែមិថុនា ឆ្នាំ1957)<br>• អនុសញ្ញាបន្ថែមស្តីពីការលុបចោលទាសភាពការជួញដូរទាសករ និងទីកន្លែង និងការបង្កើត ការប្រើប្រាស់ស្រដៀងគ្នានឹងទាសភាព (ថ្ងៃទី07 ខែកញ្ញា ឆ្នាំ1956) (ចូលជាធរមាននៅថ្ងៃទី30 ខែតុលា ឆ្នាំ1967) (ប្រទេសកម្ពុជាបានយល់ព្រមនៅថ្ងៃទី15 ខែតុលា ឆ្នាំ1992)<br>•<br>អនុសញ្ញាស្តីពីការគាបសង្កត់ និងការដាក់ទណ្ឌកម្មនៃឧក្រិដ្ឋកម្មក្នុងរបប Apartheid (ថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ1973) (ចូលជាធរមាននៅថ្ងៃទី18 ខែកក្កដា ឆ្នាំ1976) (ប្រទេសកម្ពុជាបានយល់ព្រមនៅថ្ងៃទី28 ខែកក្កដា ឆ្នាំ1981)<br>•<br>លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការយុត្តិធម៌អន្តរជាតិ ICJ (ថ្ងៃទី17 ខែកក្កដា ឆ្នាំ1998) (ចូលជាធរមាននៅថ្ងៃទី01 ខែកក្កដា ឆ្នាំ2002) (ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី11 ខែមេសា ឆ្នាំ2002)<br>• អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (ថ្ងៃទី31 ខែតុលា ឆ្នាំ2003) (ចូលជាធរមាននៅថ្ងៃទី14 ខែធ្នូ ឆ្នាំ2005) (ប្រទេសកម្ពុជាបានយល់ព្រមនៅថ្ងៃទី05 ខែកញ្ញា ឆ្នាំ2007) |
| **លិខិតុបករណ៍ នានា ដែលបាន ចុះហត្ថលេខា (ជ្រើសរើស)** | • ICRMW ៖ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ (ថ្ងៃទី18 ខែធ្នូ ឆ្នាំ1990) (ចូលជាធរមាននៅថ្ងៃទី01 ខែកក្កដា ឆ្នាំ2003)<br>• OP-ICCPR ៖ ពិធីសារបន្ថែម-កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ថ្ងៃទី 16 ខែធ្នូ ឆ្នាំ1966) (ថ្ងៃទី23 ខែមិនា ឆ្នាំ1976) (កម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី27 ខែកញ្ញា ឆ្នាំ2004)<br>• CEDAW ៖ អនុសញ្ញាស្តីពីសិទ្ធិនយោបាយរបស់ស្ត្រី (ថ្ងៃទី31 ខែមិនា ឆ្នាំ1953) (ចូលជាធរមាននៅថ្ងៃទី07 ខែកក្កដា ឆ្នាំ1954) (កម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី11 ខែវិច្ឆិកា ឆ្នាំ2001)<br>• អនុសញ្ញាស្តីពីសញ្ជាតិរបស់ស្ត្រីរៀបការរួច (ថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ1957) (ចូលជាធរមាននៅថ្ងៃទី11 |

| | |
|---|---|
| | ខែសីហា ឆ្នាំ1958) (កម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី11 ខែវិច្ឆិកា ឆ្នាំ2001)<br>• CRPD ៖ អនុសញ្ញាស្តីពីសិទ្ធិជនពិការ (ថ្ងៃទី13 ខែធ្នូ ឆ្នាំ2006) (ចូលជាធរមាននៅថ្ងៃទី03 ខែឧសភា ឆ្នាំ2008)<br>• OP-CRPD ៖ ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ(ថ្ងៃទី13 ខែធ្នូ ឆ្នាំ2006) (ចូលជាធរមាននៅថ្ងៃទី03 ខែឧសភា ឆ្នាំ2008) |
| មិនបានចុះហត្ថលេខា | • PED ៖ អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (ថ្ងៃទី20 ខែធ្នូ ឆ្នាំ2006) (ចូលជាធរមាននៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2010) |

# និដ្ឋភាពទូទៅ

## ១.	រចនាសម្ព័ន្ធនីតិរដ្ឋសំខាន់ៗ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីប្បញ្ញត្តិជាច្រើនដែលសមស្របនឹងសូចនាករគន្លឹះនៃនីតិរដ្ឋ ដូចមាននៅក្នុងផ្នែក "ក" នៃរបាយការណ៍នេះ។ កម្ពុជា គឺជាប្រទេសរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលបានប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។[iii] សំខាន់ជាងនេះ នៅក្នុងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញគឺការប្រកាន់យករបបដែលទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ជាពិសេស ការធានាភាពស្មើគ្នាចំពោះមុខច្បាប់ និងសិទ្ធិរបស់ជនជាប់ចោទ ការហាមឃាត់ការឃុំឃាំងខុសច្បាប់ និងរាល់ទម្រង់នៃការរើសអើង និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការធ្វើដំណើរឆ្ងាយជិត សិទ្ធិបង្កើតសមាគម ជំនឿសាសនា និងទ្រព្យសម្បត្តិ រួមទាំង សន្តិសុខ។[iv] បន្ថែមលើយន្តការជាតិ ប្រទេសកម្ពុជាក៏បានទទួលស្គាល់ និងអនុវត្តយន្តការតំបន់អាស៊ាន[v] និងយន្តការអន្តរជាតិ (UN Charter, UDHR, ICCPR, ICESCR, CEDAW, CRC, etc.)[vi] ដើម្បីធានានូវការគោរពការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ប្រទេសកម្ពុជា ក៏បានព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ក្នុងការអនុញ្ញាតឲ្យមានការត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្ស តាមរយៈរបាយការណ៍របស់អ្នករាយការណ៍ពិសេស[vii] (កាលពីអតីតសំដៅលើអ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសម្រាប់ប្រទេសកម្ពុជា)[viii] របាយការណ៍សំខាន់ៗ និងរបាយការណ៍ប្រចាំប្រទេស ធ្វើឡើងដោយការិយាល័យស្នងការសហប្រជាជាតិ (OHCHR)។[ix] ជាពិសេសនោះ ក៏បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការត្រួតពិនិត្យតាម Universal Periodic Rerview[x] និងក្នុងកំឡុងពេលត្រួតពិនិត្យកម្រិតស្មើគ្នា ដែលបានបញ្ចប់ទៅកាលពីថ្ងៃ ទី១៧ ខែមីនា ឆ្នាំ២០១០ ប្រទេសកម្ពុជាបានទទួលយកនូវអនុសាសន៍ទាំង ៩១ចំណុច។[xi]

ជាចុងក្រោយ មាត្រា ៥១(៤) នៃរដ្ឋធម្មនុញ្ញ បានចែងពីការបែងចែកអំណាចទាំងបីរបស់រដ្ឋ គឺ នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ រដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិច្បាប់នានា មិនត្រឹមតែកំណត់ពីការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋចំពោះមុខច្បាប់ព្រមទាំងមន្ត្រីរដ្ឋាភិបាល។[xii]

## ២.	ការកកើត និងការវិវត្តន៍របស់នីតិរដ្ឋ

ប្រព័ន្ធច្បាប់ប្រទេសកម្ពុជា បានទទួលរងនូវការអន់ថយយ៉ាងខ្លាំង ដោយសារតែគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ក្នុងការកសាងរបបកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនីស្តកម្ពុជាបានលុបបំបាត់ចោលនូវហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន និងច្បាប់នានានៃរបបមុន រួមទាំង តុលាការ។ ជំនួសប្រព័ន្ធច្បាប់មុនៗ បក្សកុំម្មុយនីស្តកម្ពុជាបានដាក់ចេញនូវប្រព័ន្ធច្បាប់មជ្ឈការផ្តាច់ការ ហើយប្រើប្រាស់អំណាចផ្តាច់ការទូទាំងប្រទេស និងក្តោបក្តាប់គ្រប់ទិដ្ឋភាពរស់នៅរបស់ប្រជាពលរដ្ឋ។ បញ្ញាវ័ន្ត គឺក្នុងចំណោមក្រុមគោលដៅ ដែលត្រូវកំចាត់ចោលក្នុងរបបនេះ ជាលទ្ធផល កម្ពុជាបានបាត់បង់អ្នកច្បាប់ជាច្រើនក្នុងសម័យនេះ។ ចាប់តាំងពីការដួលរលំនៃបក្សកុំម្មុយនីស្តកម្ពុជា និងការបញ្ចប់សង្គ្រាមស៊ីវិល ប្រព័ន្ធច្បាប់នៅកម្ពុជាមានការអភិវឌ្ឍន៍យ៉ាងខ្លាំង។

ការដួលរលំនៃសហភាពសូវៀតនៅឆ្នាំ១៩៨៩ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាំឲ្យមានកត្តាប្រវត្តិសាស្រ្តចម្បងពីរនាំឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា បន្ទាប់ពីរយៈពេលជាងមួយទសវត្សនៃរបបកុំម្មុយនីស្ត/សង្គមនិយម (១៩៧៥-១៩៧៩, ១៩៧៩-១៩៨៩ និង ១៩៨៩-១៩៩៣)។[xiii] រដ្ឋាភិបាលនាពេលបច្ចុប្បន្ន បានឈ្នះឆ្នោតនៅឆ្នាំ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ២០០៨។ គោលបំណងចម្បងមួយនៃក្របខណ្ឌគោលនយោបាយផ្អែកលើយុទ្ធសាស្រ្តត្រីកោណ (នៅឆ្នាំ១៩៩៨ ផ្តោតសំខាន់លើសន្តិភាពផ្ទៃក្នុង និងស្ថេរភាព ក៏ដូចជា ការអភិវឌ្ឍន៍ប្រកបដោយចីរភាព) និងក្រោយមកវិវត្តន៍ទៅជាយុទ្ធសាស្រ្តចតុកោណ (ជំហានទី១ ក្នុងឆ្នាំ២០០៤ និងជំហានទី២ ក្នុងឆ្នាំ២០០៨) ទាក់ទងនឹងកំណែទម្រង់ប្រព័ន្ធតុលាការ រដ្ឋបាល និងកំណែទម្រង់ច្បាប់។[xiv] ការខិតខំធ្វើឲ្យមានកំណែទម្រង់ប្រព័ន្ធតុលាការ គឺការបង្កើតឲ្យមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងឆ្នាំ

២០០០[xv] និងការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក៏ដូចជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។[xvi]

ស្ថាប័នច្បាប់ និងស្ថាប័នតុលាការកម្ពុជា កំពុងស្ថិតនៅក្នុងការផ្លាស់ប្តូរ និងភាពទន់ខ្សោយនៃប្រព័ន្ធតុលាការកម្ពុជា ដោយសារឥទ្ធិពលពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ការកសាងឡើងវិញនូវស្ថាប័ននយោបាយ ដែលរងការខ្ទេចខ្ទាំពីរបបខ្មែរក្រហម បានធ្វើឲ្យកម្ពុជាជួបភាពលំបាកយ៉ាងខ្លាំង ដោយកង្វះធនធានមនុស្ស ថវិកា និងសម្ភារៈ។

អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា លោក Surya Subedi បានមកទស្សនកិច្ចនៅប្រទេសកម្ពុជានៅ ខែមិថុនា ឆ្នាំ២០១០ និងបានចេញសេចក្តីថ្លែងការណ៍មួយ ដែលគូសបញ្ជាក់អំពីការព្រួយបារម្ភយ៉ាងខ្លាំងជុំវិញបញ្ហាប្រព័ន្ធច្បាប់នៅកម្ពុជា ៖ "កង្វះធនធានលើគ្រប់វិស័យ ភាពទន់ខ្សោយនៃអង្គការ និងស្ថាប័ន កង្វះនូវការយល់ដឹងអំពីស្តង់ដារសិទ្ធិមនុស្ស ការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ កង្វះហិរញ្ញវត្ថុ ក៏ដូចជា កង្វះក្នុងការអនុវត្តន៍ច្បាប់បានធ្វើឲ្យស្ថាប័នតុលាការពុំទទួលបានជំនឿទុកចិត្តពីសំណាក់ប្រជាជនពីគ្រប់មជ្ឈដ្ឋាន"។[xvii]

ការអភិវឌ្ឍន៍ដ៏សំខាន់នៅកម្ពុជា ដើម្បីដោះស្រាយនូវភាពទន់ខ្សោយទាំងនេះ និងបង្កើតវប្បធម៌ទទួលខុសត្រូវចំពោះមុខច្បាប់ និងនីតិរដ្ឋ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦។ **អ.វ.ត.ក** បង្កើតឡើងក្រោមរូបភាពជាតុលាការកូនកាត់ ដែលមានចៅក្រម និងមេធាវី (ជាតិ និងអន្តរជាតិ) ក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងបណ្តាអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[xviii][xix] (សូមមើលនៅក្នុងផ្នែកខាងក្រោមស្តីពី **អ.វ.ត.ក** និងនីតិរដ្ឋ)

បន្ថែមលើនេះ ក្រមចម្បងចំនួន ៤ រួមមាន ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ បានអនុម័តជាបន្តបន្ទាប់នៅឆ្នាំ២០០៦, ២០០៧, ២០០៧ និង ២០០៩។ ច្បាប់ថ្មីមួយដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអភិបាលកិច្ចល្អ និងនីតិរដ្ឋ គឺច្បាប់ស្តីពីការគ្រប់គ្រងរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ត្រូវបានបង្កើតនៅឆ្នាំ២០០៨ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការរៀបចំដំណើរការអំណាច ក៏ដូចជា ការទទួលខុសត្រូវ វិធានពិន័យ ការទទួលខុសត្រូវរដ្ឋប្បវេណី/ព្រហ្មទណ្ឌ ក្នុងឆ្នាំ២០០៩ និង ២០១០។ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ[xx] ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ហើយអង្គភាពប្រឆាំងនឹងអំពើពុករលួយ ក៏ត្រូវបានបង្កើតឡើង ដើម្បីស៊ើបអង្កេត និងចាត់វិធានការណ៍ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិចោទប្រកាន់ប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាលដែលប្រព្រឹត្តអំពើពុករលួយ។[xxi] ច្បាប់នេះតម្រូវឲ្យមន្ត្រីសាធារណៈ (ដែលតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ) ប្រកាសទ្រព្យសម្បត្តិ និងប្រភពចំណូលមិនឲ្យហួសពី ខែមីនា ឆ្នាំ២០១១។[xxii] ច្បាប់សំខាន់ផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ គឺកំពុងស្ថិតនៅក្នុងសេចក្តីព្រាង ដូចជា ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។[xxiii] ជាងនេះទៀត សិទ្ធិទទួលបានយុត្តិធម៌ មានការកើនឡើងតាមរយៈការបង្កើតជម្រើសក្រៅប្រព័ន្ធតុលាការ ដូចជា ការបង្កើតមជ្ឈមណ្ឌលយុត្តិធម៌នៅថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយសំណុំរឿងតូចៗ ប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល។[xxiv]

## ៣. <u>សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស</u>

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ឬចូលរួមជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិជាច្រើន ស្តីពីសិទ្ធិមនុស្ស។ នេះជាការបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការយកច្បាប់អន្តរជាតិទៅជាច្បាប់ជាតិ ឧទាហរណ៍ តាមរយៈការផ្តល់សច្ចាប័នលើពិធីសារបន្ថែមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បន្ទាប់ពីទទួលបានអនុសាសន៍ពីការត្រួតពិនិត្យ UPR ឆ្នាំ2009 ដែលបានបង្ហាញថា ឆន្ទៈរបស់រដ្ឋាភិបាលក្នុងការយកគោលការណ៍នៃអនុសញ្ញាទៅអនុវត្តតាមរយៈការចុះហត្ថលេខាលើ ICRMW, CRPD និង OP-CRPD។

ផ្អែកតាមទំនាក់ទំនងច្បាប់ក្នុងតំបន់ និងច្បាប់អន្តរជាតិ ប្រទេសកម្ពុជា គឺជាប្រទេសទ្វិនិយម ដែលតម្រូវឲ្យផ្តល់សច្ចាប័ន

លើច្បាប់អន្តរជាតិ និងចុះហត្ថលេខាដោយប្រមុខរដ្ឋាភិបាល (ឬអ្នកតំណាង) តាមរយៈការអនុម័តជាច្បាប់ (ព្រះរាជក្រម) និងដោយស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីឲ្យច្បាប់អន្តរជាតិនោះអាចមានសុពលភាពទៅបាន។[xxv] ទស្សនៈខុសៗគ្នា បានលើកឡើងពីកង្វល់នៃឋានានុក្រមច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅកម្ពុជា។ បញ្ហាទីមួយ គឺថា រដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិមានឋានៈស្មើគ្នាដូចមានចែងនៅមាត្រា ៣១(១) នៃរដ្ឋធម្មនុញ្ញ[xxvi] ហើយក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ក៏បានបកស្រាយថា ចំពោះករណីនេះតុលាការមិនត្រឹមតែមើលលើច្បាប់ជាតិទេ ក៏ត្រូវមើលលើច្បាប់អន្តរជាតិ ដែលកម្ពុជាបានទទួលស្គាល់។[xxvii] ទស្សនៈទីពីរ គឺច្បាប់អន្តរជាតិមានឋានានុក្រមទាបជាងរដ្ឋធម្មនុញ្ញ។[xxviii] ទស្សនៈទីបី នៅក្នុងកាលៈទេសៈកំរ គឺច្បាប់អន្តរជាតិអាចបំពេញនូវភាពខ្វះចន្លោះនៃច្បាប់ជាតិ ដូចមាន ចែងក្នុងមាត្រា ៦០ នៃច្បាប់ពាណិជ្ជកម្ម[xxix] និងមាត្រា ៣៣(១) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។[xxx]

| លិខិតុបករណ៍ (ចូលជាធរមាន) | ចុះហត្ថលេខា | ផ្តល់សច្ចាប័ន/ការចូលរួម (a) ឬការទទួលយក(d) | ការបម្រុងទុក | ការទទួលស្គាល់សមត្ថកិច្ចពិសេសរបស់ស្ថាប័នបង្កើតដោយសន្ធិសញ្ញា |
|---|---|---|---|---|
| ICERD(4 មករា1969) | 12 មេសា1966 | 28 វិច្ឆិកា1983 | គ្មាន | គ្មានបណ្តឹងបុគ្គល |
| ICCPR(23 មីនា1976) | 17 តុលា1980 | 26 ឧសភា1992a | គ្មាន | គ្មានបណ្តឹងរវាងរដ្ឋ និងរដ្ឋ |
| ICESCR(23 មីនា1976) | 17 តុលា1980 | 26 ឧសភា1992a | គ្មាន | N/A |
| CEDAW(3 កញ្ញា1981) | 17 តុលា1980 | 15 តុលា 1992a | គ្មាន | N/A |
| OP-CEDAW (22 ធ្នូ 2000) | 11 វិច្ឆិកា2001 | 13 តុលា 2010 | គ្មាន | មានបណ្តឹងបុគ្គល<br>នីតិវិធីស៊ើបអង្កេត |
| CAT(26 មិថុនា1987) | N/A | 15 តុលា 1992a | គ្មាន | គ្មានបណ្តឹងបុគ្គល<br>គ្មានបណ្តឹងរវាងរដ្ឋ និងរដ្ឋ<br>គ្មាននីតិវិធីស៊ើបអង្កេត |
| OP-CAT(22 មិថុនា2006) | 14 កញ្ញា2005 | 30 មីនា2007 | គ្មាន | មានបណ្តឹងបុគ្គល |
| CRC និងការធ្វើវិសោធនកម្ម (2 កញ្ញា1990) | N/A | 15 តុលា 1992a | គ្មាន | N/A |
| វិសោធនកម្មCRC មាត្រា 43(2) (18 វិច្ឆិកា 2002) | N/A | 12 សីហា1997a | គ្មាន | N/A |
| OP-CRC-AC (12 កុម្ភៈ 2002) | 27 មិថុនា2000 | 16កក្កដា2004 | គ្មាន | N/A |
| OP-CRC-SC (18 មករា2002) | 27 មិថុនា 2000 | 30ឧសភា2002 | គ្មាន | N/A |

| | | | | |
|---|---|---|---|---|
| ICRMW(1 កក្កដា 2003) | 27 កញ្ញា 2004 | គ្មាន | N/A | N/A |
| CRPD(3 ឧសភា 2008) | 1 តុលា 2007 | គ្មាន | N/A | N/A |
| OP-CRPD(3ឧសភា2008) | 1 តុលា 2007 | គ្មាន | N/A | N/A |
| CPED(23 ធ្នូ 2010) | គ្មាន | គ្មាន | N/A | N/A |

## ៤. ការបកស្រាយ និងការអនុវត្តន៍តិរដ្ឋ

គោលការណ៍នីតិរដ្ឋ គឺលែងមានភាពចំឡែកនៅកម្ពុជា ក្រោយពីចលាចលនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ និងដូចដែលសម្តេចនាយករដ្ឋមន្ត្រីបានថ្លែងថា "នេះគ្រាន់តែជាដំណើរសន្សឹមៗ ដែលកម្ពុជាត្រូវតែគោរពនូវរាល់គោលការណ៍ជាមូលដ្ឋានក្នុងសម័យកាលសាកលភាវូបនីយកម្ម និងការពឹងពាក់គ្នាទៅវិញទៅមក ដែលបញ្ចូលនីតិរដ្ឋ"។ លោក **ទេព ដារ៉ុង**[xxxi] បានឯកភាពតាមសេចក្តីថ្លែងរបស់សម្តេចនាយករដ្ឋមន្ត្រីថា នីតិរដ្ឋបានចាប់ផ្តើមអភិវឌ្ឍន៍នៅកម្ពុជាចាប់ពីឆ្នាំ១៩៩៣ និងកាន់តែមានភាពចំណាស់។[xxxii]

**សម្តេចនាយករដ្ឋមន្ត្រីបានថ្លែងថា[xxxiii] ៖**

*"នីតិរដ្ឋ គឺជាបណ្តុំនៃការអនុវត្តន៍ និងការបង្កើតស្ថាប័ន ដែលនាំមកនូវសណ្តាប់ធ្នាប់សង្គមសម្រាប់ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋ"។ "គោលគំនិតនេះក៏ពាក់ព័ន្ធនឹងការអនុវត្តន៍ដែលប្រើសិទ្ធិ និងកាតព្វកិច្ច និងការប្រើប្រាស់អំណាចឲ្យបានត្រឹមត្រូវ"។*

ឯកសារស្តង់មតិថ្នាក់ជាតិនៅឆ្នាំ២០០៧ បានលើកឡើងថាការគាំទ្រនីតិរដ្ឋ[xxxiv] មានការសាយភាយគួរឲ្យកត់សម្គាល់ទូទាំងប្រទេសកម្ពុជា ជាពិសេស ក្នុងអំឡុងពេលកាត់ទោសមេដឹកនាំខ្មែរក្រហម។[xxxv] ឯកសារនេះក៏បានបន្តថា វប្បធម៌នយោបាយគោរពនីតិរដ្ឋ បានកសាងឡើងបានយ៉ាងល្អនៅកម្ពុជា។[xxxvi] លោក Gibson បានថ្លែងថា "ប្រជាពលរដ្ឋកម្ពុជាភាគច្រើនហាក់ដូចជាមានទស្សនៈថា [...]នីតិរដ្ឋ គឺជាតម្លៃនយោបាយដ៏វិជ្ជមាន និងគួរឲ្យចង់បាន ទោះបីជាតថភាពជាក់ស្តែងក្នុងសង្គមកម្ពុជាមានអំពើពុករលួយ និងការមិនគោរពច្បាប់"។[xxxvii] ទិដ្ឋភាពមួយនៃនីតិរដ្ឋ គឺថា គុណតម្លៃសម្រាប់ប្រជាពលរដ្ឋកម្ពុជា គឺនាំយកមេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្ស។[xxxviii]

***ជំហររបស់រដ្ឋាភិបាលទាក់ទងនឹងនីតិរដ្ឋ ត្រូវបានចែងយ៉ាងច្បាស់ថា ៖***

*"តាមរយៈការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសវនាការសាធារណៈ និងការផ្តន្ទាទោសចំពោះអ្នកទទួលខុសត្រូវខ្ពស់បំផុត តុលាការនឹងជួយពង្រឹងនីតិរដ្ឋ និងបង្ហាញជាឧទាហរណ៍ជាក់ស្តែងដល់បុគ្គលដែលមិនគោរពច្បាប់នៅប្រទេសកម្ពុជា និងរបបព្រៃផ្សៃនានានៅទូទាំងពិភពលោក"។[xxxix]*

ការយល់ឃើញរបស់រដ្ឋាភិបាលកម្ពុជាអំពីនីតិរដ្ឋ សម្តេចនាយករដ្ឋមន្ត្រី និងលោក **ដារ៉ុង** បានថ្លែងស្រដៀងគ្នានៅក្នុងអត្ថបទបោះពុម្ពផ្សាយមួយថា នីតិរដ្ឋមានធាតុសំខាន់ៗចំនួន ៣[xl] គឺ ៖

១. ការប្រមូលច្បាប់ចងក្រងជាក្រម និងកំណត់ឋានានុក្រមច្បាប់ឲ្យបានច្បាស់ ដើម្បីធានានូវសិទ្ធិ និងកាតព្វកិច្ច។[xli]

២. ច្បាប់ត្រូវតែមានការប្រកាសផ្សាយ មានការយល់ដឹង និងគាំទ្រពីប្រជាពលរដ្ឋ។

៣. ការអនុវត្តន៍ច្បាប់ត្រូវតែមានភាពត្រឹមត្រូវ មានប្រសិទ្ធិភាព សមភាព និងអាចព្យាករណ៍បាន។ បន្ថែមលើនេះ គឺទាមទារនូវយន្តការពង្រឹងការអនុវត្តន៍ឲ្យបានត្រឹមត្រូវដូចជា នគរបាល អង្គភាពយុត្តិធម៌...ជាដើម។

ម៉្យាងទៀតយុទ្ធសាស្ត្រក្នុងការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌[xlii] គឺមានសារៈសំខាន់ ដើម្បីសម្រេចបាននូវនីតិរដ្ឋ។ យោងតាមធនាគារពិភពលោក នីតិរដ្ឋ គឺជាធាតុដ៏សំខាន់មួយក្នុងការកសាងអភិបាលកិច្ចល្អសម្រាប់ប្រទេសជាតិ[xliii] និងលោកនាយករដ្ឋមន្ត្រី បានអះអាងថា រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ គឺដើម្បីអភិបាលកិច្ចល្អដែលនាំឲ្យការអនុវត្តន៍នីតិរដ្ឋបានកាន់តែប្រសើរ។[xliv] លោកនាយករដ្ឋមន្ត្រីទទួលស្គាល់ថា សម្មិទ្ធិផលនាពេលបច្ចុប្បន្ន គឺគួរឲ្យកត់សម្គាល់ ក៏ប៉ុន្តែតម្រូវឲ្យមានការពង្រឹងបន្ថែម និងធ្វើឲ្យឆាប់រហ័ស។[xlv] លោកនាយករដ្ឋមន្ត្រីបានបន្តថា ឆន្ទៈនយោបាយច្បាស់លាស់ គឺនឹងធ្វើឲ្យនីតិរដ្ឋក្លាយជាការពិត ៖

> "ផ្លូវនេះមានការលំបាក និងមានឧបសគ្គ ប៉ុន្តែយើងគ្មានផ្លូវផ្សេង [ដែលមានប្រសិទ្ធភាពជាងនេះ] ឬវិធីផ្សេង [ដើម្បីសម្រេចគោលបំណងរបស់ប្រជាពលរដ្ឋ]"។ "ផ្លូវលំបាក តែគ្មានវិធីផ្សេងទេ" ដោយមិនគិតពីភាពលំបាក និងកង្វះខាតធនធាន (សមត្ថភាព និងថវិកា) ដែលជាការសម្រេចចិត្តនយោបាយមួយដ៏ច្បាស់លាស់ និងមុតមាំ។[xlvi]

ទោះបីជារដ្ឋាភិបាលអះអាងពីការប្តេជ្ញាចិត្តចំពោះនីតិរដ្ឋ ក៏អ្នកនាំពាក្យពិសេស ឯកឧត្តម **កែវ ពុទ្ធរស្មី**[xlvii] និងឯកឧត្តម **សឹន សូប៊ែរ្ត៍**[xlviii] មានគំនិតស្របគ្នាថា ទស្សនៈប្រជាជនចំពោះនីតិរដ្ឋ គឺថា ទោះបីជាមានច្បាប់ជាច្រើន ប៉ុន្តែការអនុវត្តន៍ជារឿងមួយដោយឡែក។[xlix] ទំនោរនៃការជំនុំជម្រះភាគច្រើនគឺទេរទៅអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច ដោយសារការរីករាលដាលនៃអំពើពុករលួយ ដែលជាកត្តាមួយក្នុងចំណោមកត្តាចម្បងៗ ធ្វើឲ្យចុះថយនូវជំនឿចិត្តរបស់សាធារណជនចំពោះនីតិរដ្ឋ។[l] នីតិរដ្ឋមានពីររូបភាព[li] ៖

១. ការសម្រេចចិត្តទៅតាមទស្សនៈមតិភាគច្រើន ប៉ុន្តែគោរពទស្សនៈរបស់មតិភាគតិច។

២. ពង្រីករចនាសម្ព័ន្ធក្នុងការផ្តល់សេវានានា (សុខមាលភាព ការអប់រំ និងការស្រាវជ្រាវឃ្លាំមើល) ដើម្បីអប់រំប្រជាជន និងធានានូវមនសិការប្រកបដោយសីលធម៌ និងពលរដ្ឋល្អ។

តាមទស្សនៈនេះ សហគមន៍អន្តរជាតិ ប្រជាពលរដ្ឋ អង្គការសិទ្ធិមនុស្ស និងអង្គការក្រៅរដ្ឋាភិបាល ដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងនីតិរដ្ឋ ដោយសារវាអាចសម្រេចបានតាមរយៈការអប់រំ ការធានានូវការបែងចែកអំណាច ការលើកកម្ពស់ សេរីភាពសារព័ត៌មាន និងការរីកចម្រើនសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។[lii]

បន្ថែមលើនេះ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះនីតិរដ្ឋ អាចឆ្លុះបញ្ចាំងតាមរយៈការបែងចែកកញ្ចប់ថវិកាជាតិ ឆ្នាំ២០១១ សម្រាប់ក្រសួងយុត្តិធម៌ (ប្រហែលជា ៩លានដុល្លាអាមេរិក = ០.៨២% នៃថវិកាជាតិ)។[liii]

| សូចនាករ | តួលេខ |
|---|---|
| ចំនួនចៅក្រមក្នុងប្រទេស | • តុលាការកំពូល៖ ចៅក្រមចំនួន ១៦រូប (ស្ត្រី ២រូប) និងព្រះរាជអាជ្ញាចំនួន ៧រូប<br>• សាលាឧទ្ធរណ៍៖ ចៅក្រមចំនួន ១៦ រូប (ស្ត្រី ២ រូប) និងព្រះរាជអាជ្ញាចំនួន ៩ រូប<br>• សាលាដំបូង៖ ចៅក្រមចំនួន ១៦១រូប និងព្រះរាជអាជ្ញាចំនួន ៧៦រូប<br>*យោងតាមគេហទំព័ររបស់សាលាភូមិន្ទវិជ្ជាជីវៈចៅក្រម នៅឆ្នាំ២០១១ ចៅក្រមសរុបទាំងអស់មានចំនួន ៣៩៦រូប |
| ចំនួនមេធាវីក្នុងប្រទេស(ខែកុម្ភៈ ឆ្នាំ២០១១) | • មេធាវីពេញសិទ្ធិ = ៥៩៨រូប (ស្ត្រី ១០៨រូប)<br>• មេធាវីកំពុងធ្វើកម្មសិក្សា = ៥៥រូប (ស្ត្រី ៧រូប)<br>• មេធាវីសុំមិនប្រកបវិជ្ជាជីវៈដោយមូលហេតុវិសមិតភាព ៣៣រូប (ស្ត្រី ២រូប)<br>• មេធាវីសុំនៅក្រៅបញ្ជី ៣៦រូប (ស្ត្រី ៨រូប)<br>• មេធាវីដែលបានលុបឈ្មោះពីគណៈមេធាវី ៣៣រូប (ស្ត្រី ៦រូប)<br>សរុប៖៧៥១រូប (ស្ត្រី ១២៧រូប) |
| ការជ្រើសរើសមេធាវីដោយគណៈមេធាវីប្រចាំឆ្នាំ? ការចំណាយ/តម្លៃសិក្សា? | • ចំនួនមេធាវីក្នុងការជ្រើសរើសពី ៣០-៤៥រូប (៤៨រូប ក្នុងឆ្នាំ ២០១០)<br>តម្លៃសម្រាប់ការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី<br>៨០០ - ១០០០ ដុល្លារអាមេរិក (ជំនាន់ទី១០ និងទី១១)<br>***សម្គាល់៖** ការជ្រើសរើសសិស្សចៅក្រមប្រចាំឆ្នាំ សម្រាប់សាលាភូមិន្ទចៅក្រម គឺ ៥៥រូប។ ចៅក្រម គឺជាមន្ត្រីសាធារណៈ ដូច្នេះបេក្ខជនពុំតម្រូវឲ្យបង់ប្រាក់សិក្សាឡើយ និងទទួលបានបៀវត្សរ៍ប្រចាំខែចំនួន ៧៥ដុល្លាបន្ថែមទៀត។ |
| រយៈពេលស្តង់ដារម្រាប់ការសិក្សា/សញ្ញាបត្រ | • គុណវឌ្ឍិដើម្បីក្លាយជាចៅក្រម ត្រូវតែផ្អែកលើការបញ្ចប់ការបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រម។ វិញ្ញាសារមួយក្នុងចំណោមវិញ្ញាសារចំនួនពីរ សម្រាប់ការប្រឡងចូលសាលាភូមិន្ទចៅក្រម គឺការប្រឡងផ្ទាល់មាត់ (ចំណេះដឹងទូទៅ) ស្តីពីសិទ្ធិមនុស្ស |

| | |
|---|---|
| | ទស្សនៈទូទៅនៃនីតិរដ្ឋ និងយុត្តិធម ព្រមទាំងច្បាប់ និងយុត្តិធម៌។រយៈពេលនៃការបណ្តុះបណ្តាលគឺ ២៤ខែ (សិក្សាទ្រឹស្តីច្បាប់ ៨ខែ កម្មសិក្សានៅតុលាការ ១២ខែ និងវគ្គបណ្តុះបណ្តាលជំនាញឯកទេស ចំនួន ៤ខែទៀត)។<br><br>• គុណវឌ្ឍិដើម្បីក្លាយជាមេធាវី ត្រូវតែផ្អែកលើការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ឬតាមរយៈបទពិសោធន៍។ ចាប់ពីឆ្នាំ២០០២ ការបណ្តុះបណ្តាលសម្រាប់មេធាវី (ជំនាន់ទី៤) ធ្វើនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីនៃគណៈមេធាវី។ ការបណ្តុះបណ្តាលដោយការសិក្សាក្នុងសាលាចំនួន ៩ខែ និងចុះកម្មសិក្សា ចំនួន ១ឆ្នាំ និងការបណ្តុះបណ្តាលពិសេសចំនួន ៣ខែ។ |
| **ទទួលបានវគ្គបណ្តុះបណ្តាលក្រោយក្លាយខ្លួនជាអ្នកវិជ្ជាជីវៈ** | • បច្ចុប្បន្ននេះ មិនមានការតម្រូវឲ្យចៅក្រមទទួលការបណ្តុះបណ្តាលច្បាប់បន្តទេ ប៉ុន្តែតាមរយៈកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នបរទេសវគ្គបណ្តុះបណ្តាលពិសេសស្តីពីក្រមចម្បងៗទើបតែប្រកាសឲ្យប្រើចំនួន ៤ (ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ) ត្រូវបានរៀបចំឡើង ហើយការបណ្តុះបណ្តាល (នាពេលដ៏ខ្លីខាងមុខ) សម្រាប់ច្បាប់ពិសេសដូចជាច្បាប់រដ្ឋបាលច្បាប់ការងារ និងច្បាប់យុត្តិធម៌អនីតិជន ក៏នឹងរៀបចំផងដែរ។<br><br>• ការអប់រំច្បាប់បន្តសម្រាប់មេធាវីក៏មិនតម្រូវដែរ ប៉ុន្តែអាចមានជាការរៀបចំសិក្ខាសាលា ដោយគណៈមេធាវីជាមួយដៃគូសហការនានាដូចជា JICA, IBJ ជាដើម។ |
| **រយៈពេលជាមធ្យមពីការចាប់ខ្លួនដល់ការជំនុំជម្រះ** | • មានរយៈពេលរវាងពី ២ខែ ទៅ ៦ខែ និងមិនឲ្យលើសពី ១៨ខែ ប្រសិនបើរកឃើញថា ពុំមានហេតុផលសមរម្យក្នុងការឃុំខ្លួនបន្ថែម ព្រះរាជអាជ្ញា ឬចៅក្រមអាចប្រឈមមុខនឹងការដាក់ទណ្ឌកម្មវិន័យ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបទរំលោភលើនីតិវិធីច្បាប់។<br><br>• មានរយៈពេលលើសពី ១ឆ្នាំ សម្រាប់ករណីពិសេស ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ករណី ០០១ និងករណី ០០២)។ |
| **រយៈពេលជាមធ្យមនៃការជំនុំជម្រះក្តី (ចាប់ពីបើកសវនាការរហូតដល់** | • សវនាការ គឺមានរយៈពេលខ្លី ជាធម្មតាបញ្ចប់ក្នុងរយៈពេល ១ថ្ងៃ និងអាចការប្រកាសសាលក្រមនៅក្នុងថ្ងៃដដែលនោះ។ រយៈពេលនៃការប្រែប្រួល គឺមានតែការឃុំខ្លួនបណ្តោះអាសន្ន។ |

| | |
|---|---|
| ប្រកាសសាលក្រម | • រយៈពេលលើសពី ១ឆ្នាំ ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| ការទទួលបានសាលក្រមជាសាធារណៈ | • កាលពីអតីតកាល គឺមិនអាចទទួលបានឯកសារថតចម្លងនៃសាលក្រមសម្រាប់រឿងក្តីសាលក្រមប្រគល់ឲ្យតែភាគីនៃរឿងក្តីតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាការស្នើសុំអាចធ្វើឡើងបាន ហើយសំណើនោះនឹងត្រូវបញ្ជូនទៅប្រធានតុលាការតាមរយៈក្រឡាបញ្ជី។ ប្រសិនបើច្បាប់ថតចម្លងនៃសាលក្រមត្រូវបានផ្តល់រាល់ឈ្មោះពិតប្រាកដ ឬអត្តសញ្ញាណ នឹងត្រូវបានលុបចោល។ តម្លៃថតចម្លងក៏ជាបញ្ហាមួយក្នុងការចង់ដឹងពីរឿងក្តីតុលាការ។<br><br>• ការផ្សព្វផ្សាយសាលដីកានៃតុលាការកំពូល បានចាប់ផ្តើមតាំងពីឆ្នាំ២០១០ និងបន្តនៅក្នុងឆ្នាំ២០១១។ ប្រព័ន្ធនេះកំពុងស្ថិតក្រោមការអភិវឌ្ឍន៍ ដែលមានការអភិវឌ្ឍន៍គេហទំព័រថ្មីរបស់តុលការកំពូលក្នុងការដាក់បង្ហោះសេចក្តីសម្រេចនានា។ |
| រចនាសម្ព័ន្ធតុលាការ (ប្រភព៖ គម្រោងយុត្តិធម៌ឯករាជ្យរបស់ ADB តារាងរចនាសម្ព័ន្ធរបស់តុលាការខែតុលា ឆ្នាំ២០១១ ទំព័រ ៣១។ សម្គាល់ ៖ គិតត្រឹមឆ្នាំ២០១១ មានតុលាការខេត្ត-ក្រុង ចំនួន ២១) | <br><br>ឋានានុក្រមនៃតុលការមានសមត្ថកិច្ច<br><br>ការត្រួតពិនិត្យទណ្ឌកម្មវិន័យ |
| សំណុំរឿងក្តីនៅគណកម្មាការសិទ្ធិមនុស្ស | គ្មាន |

| | |
|---|---|
| ថ្នាក់ជាតិ ឬគណកម្មាការឯករាជ្យដទៃទៀត (ប្រសិនបើមាន) | |
| ពាក្យបណ្តឹងប្រឆាំងប៉ូលីសមន្ត្រីសាធារណៈឬស្ថាប័នរដ្ឋ (ប្រចាំឆ្នាំ)? តើដោះស្រាយបានប៉ុន្មាន? | គ្មាន |

## ក. ការប្រតិបត្តិរបស់រដ្ឋក្នុងការអនុវត្តន៍គោលការណ៍ទាំង ៤ របស់នីតិរដ្ឋសម្រាប់សិទ្ធិមនុស្ស

### ១. រដ្ឋាភិបាល និងមន្ត្រីរាជការ ព្រមទាំងភ្នាក់ងារម្នាក់ៗទទួលខុសត្រូវចំពោះមុខច្បាប់

#### ១.១. តើអំណាចរបស់រដ្ឋាភិបាលត្រូវបានចែង និងកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ជាមូលដ្ឋានគ្រឹះដទៃទៀតដែរឬទេ?

អំណាចរបស់រដ្ឋ រួមមានអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ អំណាចនេះ ត្រូវបានចែង និងកំណត់ដោយរដ្ឋធម្មនុញ្ញ។ មាត្រា ៥១ បានចែងច្បាស់ពីគោលការណ៍នៃការបែងចែកអំណាច និងការអនុវត្តន៍អំណាចដោយប្រជាជនតាមរយៈអង្គទាំងបី[liv]។ ឧទាហរណ៍ខ្លះៗនៃគោលការណ៍ទាំងនេះ រួមមានដូចជា ស្វយ័តភាពនៃថវិកា[lv] បទបញ្ជាផ្ទៃក្នុងសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័ននីតិប្បញ្ញត្តិ[lvi] អភ័យឯកសិទ្ធិសភា[lvii] ព្រមទាំងការប្រកាសសង្គ្រាម ការប្រកាសអាសន្ន។ ទោះបីជាយ៉ាងណាដោយសារជាប្រទេសប្រកាន់របបសភានិយម សមាជិកសភាកម្ពុជាមិនត្រូវបានអនុញ្ញាតឲ្យបម្រើការនៅក្នុងស្ថាប័នណាផ្សេងលើកលែងតែក្នុងស្ថាប័ននីតិប្រតិបត្តិ[lviii]។ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ[lix] បានចែងពីគោលការណ៍ត្រួតពិនិត្យឲ្យមានសមតុល្យរវាងស្ថាប័នទាំងបី។

អំណាចរបស់ស្ថាប័ននីតិប្បញ្ញត្តិ ត្រូវបានចែងយ៉ាងលម្អិតនៅក្នុងរដ្ឋធម្មនុញ្ញ ចំណែកឯការរៀបចំ និងប្រព្រឹត្តទៅរបស់អំណាចនីតិប្រតិបត្តិ[lx] និងអំណាចតុលាការ[lxi] មានចែងនៅក្នុងច្បាប់ដាច់ដោយឡែក។ ជាងនេះទៀត បទប្បញ្ញត្តិពាក់ព័ន្ធនឹងអំណាចតុលាការ មានចែងកំណត់អំពីតួនាទី និងសិទ្ធិអំណាចរបស់ស្ថាប័នយុត្តិធម៌ (ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងអំណាចផ្តាច់មុខក្នុងការជំនុំជម្រះក្តី) គោលការណ៍គ្រឹះ (ឯករាជភាព និងភាពមិនលំអៀង) ការផ្តល់អំណាចដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការតែងតាំង ការដកហូតដំណែង ការចាត់វិធានការណ៍ដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា។

ទោះបីជាបទប្បញ្ញត្តិដែលបានលើកឡើងខាងលើ បានបង្កើតនូវឯករាជភាពនៃប្រព័ន្ធយុត្តិធម៌ក៏ដោយ ក៏ក្នុងការអនុវត្តន៍ជាក់ស្តែង នៅមានករណីចម្រូងចម្រាសជាច្រើនស្តីពីការជ្រៀតជ្រែកពីអំណាចនីតិប្រតិបត្តិទៅក្នុងការងាររបស់អំណាចផ្សេងៗ។[lxii] ករណីសំខាន់មួយ គឺការជ្រៀតជ្រែកដោយប្រយោលរបស់នាយករដ្ឋមន្ត្រី ដោយពុំអនុញ្ញាតឲ្យមានការចោទប្រកាន់បន្ថែម ក្រៅពីជនជាប់ចោទ ៥រូប ដែលកំពុងស្ថិតនៅការជំនុំជម្រះក្តី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយផ្អែកលើមូលហេតុស្ថេរភាពសង្គម។[lxiii] ផ្ទុយទៅវិញ ទោះបីជា មានការប្រកាសពីការមិនជ្រៀតជ្រែក ឧទាហរណ៍ នៅកំឡុងឆ្នាំកន្លងមក លោកនាយករដ្ឋមន្ត្រីបានប្រកាសជាសាធារណៈថា រដ្ឋាភិបាលនឹងមិនជ្រៀតជ្រែកនៅក្នុងសំណុំរឿងក្តីកំពុងដំណើរការនោះទេ (ដូចជា សវនាការលើជនជាតិថៃ[lxiv] សំណុំរឿងចោទប្រកាន់លោក **ហ៊ុន ហ៊ាន** ដែលជាអតីតនគរបាលប្រឆាំងគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ[lxv] និងសំណុំរឿងចោទប្រកាន់មេដឹកនាំគណបក្សប្រឆាំងពីបទដកបង្គោលតម្រុយព្រំដែន នៅតាមព្រំប្រទល់ប្រទេសវៀតណាម និងការផ្សព្វផ្សាយផែនទីនៅក្នុងគេហទំព័ររបស់ខ្លួន តុលាការកំពូលបានរកឃើញថា ការចោទប្រកាន់នេះជាការខុសច្បាប់ ព្រោះពុំមានការរំលោភព្រំប្រទល់ពីប្រទេសវៀតណាមមកលើដីកម្ពុជាទេ)។

#### ១.២. តើច្បាប់កំពូលអាចត្រូវបានធ្វើវិសោធនកម្ម ឬព្យួរការអនុវត្តន៍ ដោយអនុលោមតាមវិធាន និងនីតិវិធីដែលបានចែងដែរឬទេ?

ការសើរើ ឬការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ អាចធ្វើបានដោយអនុលោមតាមវិធាន និងនីតិវិធី ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ជំពូកទី១៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិឲ្យមានអានុភាពក្នុងការសើរើ និងការ

ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ជាពិសេស មាត្រា ១៥១(១) បានចង្អុលបង្ហាញថា អ្នកដែលអាចផ្តួចផ្តើមឲ្យមានការសើរើ ឬការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ រួមមានដូចជា ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ដោយមានការស្នើឡើងពីសមាជិករដ្ឋសភា ១/៤។ ជាងនេះទៀត ការសើរើ ឬការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវតែស្របតាមរដ្ឋធម្មនុញ្ញ ដែលត្រូវមានសម្លេងគាំទ្រភាគច្រើន ២/៣ នៃសមាជិករដ្ឋសភាទាំងមូល[lxvi] និងត្រូវបានប្រកាសដោយព្រះមហាក្សត្រ បន្ទាប់ពីបានពិភាក្សាជាមួយក្រុមប្រឹក្សាធម្មនុញ្ញ។[lxvii]

បន្ថែមលើសម្លេងភាគច្រើនលើសលុប ២/៣ ការសើរើ ឬការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវបានហាមឃាត់ក្នុងករណីប្រទេសមានអាសន្ន ឬការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលមានការប៉ះពាល់ដល់សេរីភាព លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ទោះបីជាយ៉ាងណា នៅមិនទាន់មានព្រះរាជក្រិត្យណាមួយត្រូវបានអនុម័ត (ប្រកាស) ដើម្បីមិនឲ្យអនុវត្ត ឬផ្អាកជាបណ្តោះអាសន្ននូវបទប្បញ្ញត្តិណាមួយក្នុងរដ្ឋធម្មនុញ្ញឡើយ។ ផ្ទុយទៅវិញ ក្នុងខណៈដែលប្រទេសស្ថិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចធ្វើវិស្សមកាលបានទេ សមាជិកសភាត្រូវកោះប្រជុំជារៀងរាល់ថ្ងៃ និងអាចពន្យារអាណត្តិរបស់ខ្លួនបាន ក្នុងករណី ប្រទេសជាតិមិនអាចរៀបចំការបោះឆ្នោតបាន។[lxviii] សំខាន់ជាងនេះ ការហាមឃាត់មិនឲ្យធ្វើការរំលាយសភា ក្នុងកំឡុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។[lxix]

នៅក្នុងការអនុវត្តន៍ជាក់ស្តែង នីតិវិធីធ្វើវិសោធនកម្ម គឺមិនមានភាពប្រាកដប្រជា ដូចដែលអ្នកអត្ថាធិប្បាយមួយចំនួន បានអះអាងថា ច្បាប់ធម្មនុញ្ញបន្ថែម ដែលបានធ្វើវិសោធនកម្មដោយរដ្ឋសភានៅឆ្នាំ២០០៤[lxx] គឺបានរំលោភលើនីតិវិធីធ្វើវិសោធនកម្ម ព្រោះពុំបានឆ្លងកាត់ការពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញ។[lxxi] ផ្ទុយទៅវិញ ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញមានយុត្តាធិការ ឬសមត្ថកិច្ចត្រួតពិនិត្យច្បាប់ ដែលបានអនុម័ត ដោយរដ្ឋសភា ចំណែកឯច្បាប់ធម្មនុញ្ញបន្ថែម គឺមានតម្លៃស្មើគ្នានឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[lxxii]

**១.៣. តើមន្ត្រីរាជការ និងភ្នាក់ងាររដ្ឋទៀត រួមមាន នគរបាល និងមន្ត្រីយុត្តិធម៌ ទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះការប្រព្រឹត្តកំហុស រួមមាន ការប្រើប្រាស់អំណាចដោយបំពានលើប្រយោជន៍ឯកជន ការធ្វើសកម្មភាពហួសពីដែនសមត្ថកិច្ចរបស់ខ្លួន និងការរំលោភបំពានលើសិទ្ធិមូលដ្ឋានដែរឬទេ?**

បទប្បញ្ញត្តិជាច្រើននៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងយ៉ាងច្បាស់ថា ការរំលោភបំពានទៅលើនីតិវិធី (ការឆែកឆេរ ការរឹបអូស ការឃុំខ្លួន ការស៊ើបអង្កេត បទប្បញ្ញត្តិនៃជំនួយផ្នែកច្បាប់ ការវិនិច្ឆ័យទោស។ល។) បណ្តាលឲ្យភស្តុតាងដែលប្រមូលបានដោយបំពាននោះ និងសាលក្រម/សាលដីកាផ្ទុយនឹងនីតិវិធី មិនមានតម្លៃច្បាប់ និងទុកជាមោឃៈ។[lxxiii] ជាងនេះទៀតការដាក់ទណ្ឌកម្មវិន័យ ត្រូវបានអនុវត្តលើនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា ដោយអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍[lxxiv] ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ[lxxv] និងក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[lxxvi]។ ថ្មីៗនេះ មានករណីដកហូតដំណែងមន្ត្រីនគរបាលម្នាក់ ដែលមានពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀន ការកាន់កាប់អាវុធដោយខុសច្បាប់ ឬការបាញ់បោះអនាធិបតេយ្យ។[lxxvii] ការដាក់វិន័យផ្សេងទៀតលើមន្ត្រីនគរបាល គឺការដកហូតតំណែង ដោយរង់ចាំការស៊ើបអង្កេត និងចំណាត់ការតុលាការ។[lxxviii]

បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងពីស្ថានទម្ងន់ទោសជាច្រើន ដូចជា ស្ថានទម្ងន់ទោសនៃអ្នកប្រព្រឹត្តបទល្មើស។ ប្រសិនបើអ្នកប្រព្រឹត្តបទល្មើស គឺរាជការសាធារណៈ ការផ្តន្ទាទោសត្រូវមានលក្ខណៈធ្ងន់ធ្ងរជាង

សាមញ្ញជន។ បន្ថែមលើអំពើកេងបន្លំ និងអំពើពុករលួយ បទប្បញ្ញត្តិស្តីពីស្ថានទម្ងន់ទោសនេះ ក៏អនុវត្តលើរាជការសាធារណៈ និងបុគ្គលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលបានប្រព្រឹត្តបទមនុស្សឃាត អំពើហិង្សា (បង្កររបួសស្នាម) ការរំលោភសេពសន្ថវៈ។ល។[lxxix] មាត្រា ៣០ នៃក្រមនេះចែងថា ជននេះនឹងត្រូវបានផ្តន្ទាទោសដោយមិនគិតពីឋានៈនៅក្នុងជួររដ្ឋាភិបាល ឬមុខតំណែងឬលាភការ និងអាយុរបស់ពួកគេឡើយ។[lxxx]

ចាប់តាំងពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ មានការចោទប្រកាន់ជាបន្តបន្ទាប់ទៅលើនគរបាលព្រះរាជអាជ្ញា និងមន្រ្តីសាធារណៈដទៃទៀត។[lxxxi] អង្គភាពប្រឆាំងអំពើពុករលួយ បានធ្វើសកម្មភាពចាប់ខ្លួនលើកទីមួយគឺព្រះរាជអាជ្ញាអមសាលាដំបូងខេត្តពោធិសាត់ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយចោទប្រកាន់ពីបទប្រព្រឹត្តអំពើពុករលួយ ការឃុំឃាំងមនុស្សខុសច្បាប់ និងការកំហែងយកប្រាក់។[lxxxii] បន្ទាប់មក ការកើនឡើងនៃការដាក់ពាក្យបណ្តឹងជាច្រើន ដូចជា ការចោទប្រកាន់ពីបទអំពើពុករលួយលើមន្រ្តីពន្ធដារ ៣០រូប[lxxxiii] ការចោទប្រកាន់លើមន្រ្តីឃុំ-សង្កាត់ពីអំពើពុករលួយពាក់ព័ន្ធនឹងសំបុត្រអាពាហ៍ពិពាហ៍[lxxxiv] ការចោទប្រកាន់មន្ត្រីខេត្តកំពង់ធំពីការទទួលសំណូកពីការកាប់ឈើខុសច្បាប់[lxxxv] និង ការចោទប្រកាន់អតីតស្នងការនគរបាលខេត្តបន្ទាយមានជ័យពីបទប្រព្រឹត្តអំពើពុករលួយពាក់ព័ន្ធនឹងករណីជួញដូរគ្រឿងញៀន[lxxxvi]។

## <u>២. ច្បាប់ និងនីតិវិធីក្នុងការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ទណ្ឌកម្ម អាចស្វែងរកបានជាសាធារណៈ ត្រឹមត្រូវ និងមិនរំលោភបំពាន (មិនតាមទំនើងចិត្ត) ព្រមទាំងការពារសិទ្ធិជាមូលដ្ឋាន បូរណភាពរាងកាយ សេរីភាព និងសន្តិសុខបុគ្គល និងនីតិវិធីប្រកបដោយយុត្តិធម៌</u>

ច្បាប់កម្ពុជា ជាពិសេស ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំមានជំពូកដាច់ដោយឡែកកំណត់ការពារសិទ្ធិរបស់ជនជាប់-ចោទនោះទេ។ ច្បាប់ក៏មិនបញ្ជាក់ពីបទប្បញ្ញត្តិ និងនីតិវិធីក្នុងការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ទណ្ឌកម្ម ដែលសំដៅធានាការពារសិទ្ធិជាមូលដ្ឋាន ដូចជា បូរណភាពរាងកាយ សេរីភាព សន្តិសុខបុគ្គល និងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។

### ២.១. តើក្រមព្រទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (រួមទាំង វិធានការរដ្ឋបាល ដែលផ្តល់ការការពារដល់ការឃុំខ្លួនឬវិធានទោសទណ្ឌ) មានការផ្សព្វផ្សាយ និងអាចស្វែងរកបានយ៉ាងទូលាយមានបច្ចុប្បន្នភាព និងមានគ្រប់ភាសាផ្លូវការណ៍ដែរឬទេ?

បទប្បញ្ញត្តិប្រឆាំងនឹងការឃុំឃាំងតាមទំនើងចិត្ត ត្រូវបានចែងយ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ រួមមាន មូលហេតុនៃការចោទប្រកាន់ និងរយៈពេលនៃការចាប់ខ្លួន សវនាការលើការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ពន្ធនាគារ។[lxxxvii] បន្ថែមលើនេះ បទប្បញ្ញត្តិស្តីពីជំនួយផ្នែកច្បាប់ បានដើរតួនាទីចូលរួមចំណែកក្នុងការប្រឆាំងនឹងការឃុំខ្លួនតាមទំនើងចិត្ត។[lxxxviii] ច្បាប់ដែលអនុម័តដោយសភា នឹងមានអនុភាពនៅក្នុងរាជធានី និងទូទាំងប្រទេស។ ក្រម និងច្បាប់ទាំងនេះ ត្រូវបានបោះពុម្ពផ្សាយក្នុងរាជកិច្ច ចំនួន ៨លេខ ក្នុង ១ខែ និងតម្លៃប្រមាណជា ១.២៥ ដុល្លាសហរដ្ឋអាមេរិក ក្នុង ១លេខ។ ការបោះពុម្ពផ្សាយ គឺធ្វើជាភាសាខ្មែរ។ ច្បាប់ និងបទដ្ឋានគតិយុត្តិមួយចំនួនមានការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការណ៍ ពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដែលអាចស្វែងរកបាននៅ

លើគេហទំព័រ ឬជាឯកសារអេឡិចត្រូនិច។ ម្ចាស់ជំនួយក៏បានជួយឧបត្ថម្ភការបោះពុម្ពផ្សាយឯកសារច្បាប់សំខាន់ៗ ដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងច្បាប់ការងារជាដើម។[lxxxix] គេហទំព័រនៃស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងស្ថាប័នតុលាការ មិនមាន "ប្រព័ន្ធផ្ទុកទិន្នន័យច្បាប់" ទេ[xc] ប៉ុន្តែនាពេលបច្ចុប្បន្ន ការស្វែងរកច្បាប់ និងព័ត៌មានសារធារណៈ តាមគេហទំព័ររបស់ក្រសួង និងស្ថាប័ននានា មានសន្ទុះកើនឡើង។ ការខិតខំប្រឹងប្រែងចងក្រង និងផ្សព្វផ្សាយច្បាប់ ក៏ត្រូវបានធ្វើដោយស្ថាប័នមិនមែនរដ្ឋាភិបាល (ដូចជា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការ GIZ ជាដើម)[xci] និងបុគ្គលឯកជនតាមរយៈ bloggers ។ ការខិតខំប្រឹងប្រែងទាំងអស់នេះ បានជួយសម្រួលឲ្យការស្វែងរកឯកសារច្បាប់ចាស់ៗ រួមទាំង ឯកសារច្បាប់ដែលពិបាករក មកជាឯកសារអាចរកបានក្នុងទម្រង់អេឡិចត្រូនិច ឬឌីជីថល។

### ២.២. តើច្បាប់ទាំងនេះងាយរកបាន ងាយស្រួលយល់ មិនមានប្រតិសកម្ម អាចអនុវត្តបាន អាចព្យាករណ៍បានចំពោះមនុស្សគ្រប់រូប ដោយស្មើភាព (រួមទាំងអាជ្ញាធមានសមត្ថកិច្ច) និងសមស្របតាមច្បាប់ជារធមាន?

ជាគោលការណ៍ ចម្លើយតបនឹងសំណួរខាងលើ គឺជាចម្លើយវិជ្ជមាន។[xcii] មធ្យោបាយស្វែងរកច្បាប់របស់ប្រជាពលរដ្ឋ គឺនៅមានកម្រិត ដោយធ្វើឡើងតាមរយៈប្រភពដែលបានពិពណ៌នាខាងលើ (រាជកិច្ច[xciii] និងគេហទំព័រនានា) ប៉ុន្តែក៏មានការផ្តួចផ្តើមជាច្រើនកំពុងតែដំណើរការ ដើម្បីបង្កើនមធ្យោបាយស្វែងរកច្បាប់ឲ្យកាន់តែទូលាយ។ ផលវិបាក គឺថា ប្រជាពលរដ្ឋសាមញ្ញមានចំណេះដឹងនៅមានកម្រិត ក្នុងស្វែងយល់ពីប្រជុំវាក្យស័ព្ទច្បាប់ ទោះបីជាច្បាប់ទាំងឡាយត្រូវបានសរសេរជាភាសាខ្មែរ គឺថា ពាក្យឫសរបស់វាក្យស័ព្ទច្បាប់ ជាពាក្យកម្ចីពីភាសាឥណ្ឌាបុរាណ ដូចជា បាលី ឬសំស្ក្រឹត។ ជាការឆ្លើយតប ទីស្តីការគណៈរដ្ឋមន្ត្រីក៏បានខិតខំប្រឹងប្រែងក្នុងការចងក្រងសន្ទានុក្រមច្បាប់ និងធ្វើនិយាមកម្មនូវពាក្យបច្ចេកទេសច្បាប់ ដែលប្រើក្នុងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។[xciv] ជាងនេះទៀត ក៏មានកម្មវិធីពិភាក្សាច្បាប់បានចាក់បញ្ចាំងតាមស្ថានីយ៍ទូរទស្សន៍ជាតិ និងឯកជន។[xcv] បណ្តាអង្គការក្រៅរដ្ឋាភិបាល បានជួយជាវិភាគទានក្នុងការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ ក្នុងចំណោមអ្នកមានវិជ្ជាជីវៈ ក៏ដូចជាប្រជាពលរដ្ឋសាមញ្ញ ដោយផ្តោតលើបញ្ហានានា ដូចជា ក្រមព្រហ្មទណ្ឌ ច្បាប់ភូមិបាល ច្បាប់ការងារ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងបញ្ហាវិវត្តន៍ផ្សេងៗទៀត។

គោលការណ៍អប្រតិសកម្មនៃច្បាប់ និងករណីលើកលែងមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ[xcvi] ហើយដូចគ្នានឹងនិយាមក្រមព្រហ្មទណ្ឌអន្តរជាតិ ការអនុញ្ញាតឲ្យមានការអនុវត្តន៍ច្បាប់ដោយប្រតិសកម្ម ដូចជា ការអនុវត្តន៍តាមនីតិវិធីថ្មី ករណីរឿងក្តីមុនពេលចូលជាធរមាននៃក្រមនេះ និងការអនុវត្តន៍បញ្ញត្តិផ្តន្ទាទោសថ្មី ដែលអនុគ្រោះដល់ចុងចោទ។[xcvii] របាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅឆ្នាំ ២០១០ បានបង្ហាញពីសញ្ញាណល្អៗនៃការអនុវត្តន៍ច្បាប់ដោយមិនមានប្រតិសកម្ម។[xcviii]

ការវាយតម្លៃមួយចំនួនបានអះអាងថា តម្លាភាព កាលានុវត្តន៍ភាព ឬការអាចព្យាករណ៍នៃច្បាប់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា[xcix] គឺនៅមានកម្រិត។ ទោះបីជា ភាពស្មើគ្នាចំពោះមុខច្បាប់ត្រូវបានចែងក៏ដោយ[c] ក៏នៅក្នុងការអនុវត្តន៍នៅមានភាពប្រទាំងប្រទិស។ ឧទាហរណ៍ ច្បាប់ស្តីពីបទបរិហារកេរ្តិ៍ និងការផ្តល់ព័ត៌មានមិនពិត ត្រូវបានអនុវត្តចំពោះតែបុគ្គលមួយចំនួននិងមានលក្ខណៈលំអៀង ប្រឆាំងនឹងអ្នកកាសែត សកម្មជនសិទ្ធិមនុស្ស និងមេដឹកនាំនយោបាយ។

សំណុំរឿងក្តីពាក់ព័ន្ធនឹងការដកអភ័យឯកសិទ្ធិសមាជិកសភា ៣រូប ដែលមកពីគណបក្សប្រឆាំង ដើម្បីអាចចោទប្រកាន់ព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍ និងការផ្តល់ព័ត៌មានមិនពិត។[ci] ប្រភពផ្សេងទៀត បានអះអាងថា បទប្បញ្ញត្តិច្បាប់ ដូចជា ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ត្រូវបានប្រើជាញឹកញាប់ក្នុងការចោទប្រកាន់អ្នករកស៊ីផ្លូវភេទ ជំនួសឲ្យអ្នកជួញដូរមនុស្ស និងអ្នកប្រើប្រាស់គ្រឿងញៀនជួសឲ្យឈ្មួញគ្រឿងញៀន។[cii]

**២.៣. តើច្បាប់មានអំណាចរដ្ឋបាល/វិធានការបង្ការការឃុំខ្លួនបណ្តោះអាសន្ន ដោយមិនមានការចោទប្រកាន់ ឬសវនាការក្នុងអំឡុងពេលឬក្រៅអំឡុងពេលដែលប្រទេសស្ថិតនៅក្នុងភាពអាសន្ន?**

ពេលវេលាអតិបរមា ដែលត្រូវបានអនុញ្ញាតឲ្យមន្ត្រីនគរបាលអាចធ្វើការឃុំខ្លួនជនជាប់សង្ស័យ គឺរយៈពេល ៤៨ម៉ោង និងអាចពន្យាបានតែ ២៤ម៉ោង ទៀតប៉ុណ្ណោះ ប៉ុន្តែត្រូវស្នើសុំទៅព្រះរាជអាជ្ញា។ ពេលវេលាចាប់រាប់ពីពេលដែលជនសង្ស័យមកដល់ទីស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ។ ករណីលើកលែង នីតិជនអាយុក្រោមអាយុ ១៨ឆ្នាំ មិនស្ថិតក្រោមការឃុំខ្លួនទេ។[ciii] ច្បាប់កម្ពុជាក៏អនុញ្ញាតឲ្យមានការពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន ឬការឃុំខ្លួនរង់ចាំសវនាការ ប៉ុន្តែ មានការកម្រិតរយៈពេល និងមូលហេតុនៃការឃុំខ្លួននោះទេ។ ការផុតកំណត់រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ឬការខកខានរបស់ចៅក្រមស៊ើបសួរក្នុងការចង្អុលបង្ហាញភស្តុតាងក្នុងការឃុំខ្លួន នឹងនាំឲ្យមានដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ។[civ] ច្បាប់រដ្ឋធម្មនុញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានបញ្ជាក់នូវគោលការណ៍នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) អំពីការជំនុំជម្រះឲ្យបានឆាប់រហ័ស[cv] ហើយបទបញ្ញត្តិទាំងនោះ មិនបានអនុញ្ញាតឲ្យមានការឃុំខ្លួនដោយពុំមានការចោទប្រកាន់ ឬជំនុំជម្រះកំឡុងពេល ឬក្រៅអំឡុងពេលដែលប្រទេសស្ថិតនៅក្នុងស្ថានភាពភាពអាសន្ន។ ផ្ទុយមកវិញ ការចោទប្រកាន់បទព្រហ្មទណ្ឌនឹងត្រូវរំលត់នៅពេលដែលផុតអាជ្ញាយុកាលបទល្មើស។[cvi]

ការកើនឡើងនៃការឃុំខ្លួនហួសនីតិវិធី ធ្វើឲ្យមានការចង្អៀតណែននៅក្នុងពន្ធនាគារ (មើលក្នុងសូចនា ករ III)។ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) បានថ្លែងនៅក្នុងរបាយការណ៍មួយថា ក្នុងករណីខ្លះ ជនជាប់ចោទអាចត្រូវបានឃុំខ្លួនរយៈពេល ១ខែ ថែមទៀត ដើម្បីរង់ចាំការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា បន្ទាប់ពីរយៈពេលនៃការឃុំខ្លួនរង់ចាំសវនាការត្រូវបានផុតកំណត់ និងក្រោយពីសាលាដំបូងប្រកាសថា ពុំមានពិរុទ្ធភាព។[cvii]

**២.៤. តើច្បាប់ការពារជនជាប់ចោទពីការរំលោភបំពាន ឬការដាក់ទណ្ឌកម្មតាមទំនើងចិត្ត ឬហួសពីការកំណត់ដោយច្បាប់ ឬការដាក់ពិន័យ រួមមាន ការប្រព្រឹត្តដោយអមនុស្សធម៌ ការធ្វើទារុណកម្ម ការចាប់ខ្លួនតាមអំពើចិត្ត ការឃុំខ្លួនដោយគ្មានការចោទប្រកាន់ ឬជំនុំជម្រះ និងកាត់ទោសប្រហារជីវិតដោយខុសច្បាប់? តើសិទ្ធិ habeas corpus ត្រូវបានកំណត់ក្នុងកាលៈទេសៈណាដែរ?**

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងនឹងនឹងការធ្វើទារុណកម្ម និងភាពព្រៃផ្សៃផ្សេងទៀត ប្រព្រឹត្តកម្មបែបអមនុស្សធម៌ ឬថោកទាប ឬទណ្ឌកម្មផ្សេងៗ (CAT) ទោះបីជាយ៉ាងណា នៅមិនទាន់បានបង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យមួយនៅឡើយ។[cviii] ជាគោលការណ៍ មាត្រា ៣៨(៤) នៃរដ្ឋធម្មនុញ្ញកម្ពុជា បានផ្តល់នូវការការពារដល់ជនជាប់ចោទពីការប្រព្រឹត្តិបំពានលើរូបរាងកាយ ឬការបំពានផ្សេងៗ ដូចជា ការដាក់ជាទោសបន្ថែមដលើ

អ្នកជាប់ឃុំឃាំង ឬអ្នកទោស។ អ្នកប្រព្រឹត្តអំពើល្មើសមិនថាជារាជការសាធារណៈ ក៏ត្រូវផ្តន្ទាទោសដោយអនុលោមតាមក្រមព្រហ្មទណ្ឌបច្ចុប្បន្ន។[cix] លើសពីនេះ ភស្តុតាងទទួលបានតាមមធ្យោបាយមិនស្របច្បាប់ ដូចជា ការបង្ខិតបង្ខំផ្លូវកាយ ឬផ្លូវចិត្ត ត្រូវតែចាត់ទុកថាឥតបានការ។ ជាងនេះទៀត រដ្ឋធម្មនុញ្ញបានកំណត់ថា រាល់ការចោទប្រកាន់ការការចាប់ខ្លួន ឬការឃុំខ្លួនជនណាម្នាក់ អាចធ្វើទៅបាន លុះត្រាតែអនុវត្តឲ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់។[cx] ជនដែលត្រូវបានឃុំខ្លួនដោយនគរបាល ត្រូវតែដោះលែងឲ្យមានសេរីភាពដោយព្រះរាជអាជ្ញា នៅពេលផុតកំណត់រយៈពេលឃុំខ្លួន។ មន្ត្រីនគរបាលត្រូវបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញា ដើម្បីចំណាត់ការចោទប្រកាន់បន្តទៀត។[cxi] ជនដែលត្រូវបានឃុំខ្លួន អាចត្រូវបានដោះលែង នៅពេលគ្មានមូលដ្ឋានច្បាស់លាស់ក្នុងការឃុំខ្លួន ឬផុតកំណត់រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន (ឬការពន្យារពេលនៃការឃុំខ្លួន) ឬនៅពេលមានការស្នើសុំរបស់ជនត្រូវចោទ។[cxii] សិទ្ធិដែលមានចែងក្នុងមាត្រា ៣១ ដល់មាត្រា ៥០ នៃរដ្ឋធម្មនុញ្ញ ការចាប់ខ្លួន ឬនាំខ្លួនជនណាម្នាក់ទៅតុលាការត្រូវអនុលោមទៅតាមច្បាប់ ចំណែកឯករណី ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ពុំត្រូវបានកំណត់ច្បាស់លាស់នោះទេ ដូច្នេះអាចជាហេតុនាំឲ្យមានការកម្រិតសិទ្ធិ។ ចាប់តាំងពីការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ពុំទាន់មានច្បាប់ ឬអនុក្រិត្យ ប្រកាសដាក់ប្រទេសឲ្យស្ថិតក្នុងភាពអាសន្ននៅឡើយទេ (សូម្បីតែក្នុងអំឡុងពេលជាប់គាំង នយោបាយរយៈពេល ១ឆ្នាំ ពីខែកក្កដាឆ្នាំ២០០៣ ដល់ ខែមិថុនា ឆ្នាំ ២០០៤)។[cxiii]

ទោះបីជា ច្បាប់ហាមឃាត់ការប្រើប្រាស់ការធ្វើទារុណកម្មដោយមន្ត្រីនគរបាល ក្នុងការទទួលបានចម្លើយសារភាពពីជនសង្ស័យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក៏អង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានរាយការណ៍ថា ការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តយ៉ាងទូលំទូលាយ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានកត់សម្គាល់ថា ករណីនៃការធ្វើទារុណកម្មលើផ្លូវកាយ ឬផ្លូវចិត្ត ពុំត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្មទេ។[cxiv]

### ២.៥. តើច្បាប់បានបញ្ញត្តិពីការសន្មតទុកជាមុនថាគ្មានទោសដែរឬទេ?

ច្បាប់សន្មតថា ជនជាប់ចោទជាជនស្លូតត្រង់គ្មានទោស រហូតដល់មានសាលក្រមស្ថាពរពីតុលាការ ដែលសម្រេចថា មានពិរុទ្ធភាព។ ចំណែកវិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។[cxv] ឧទាហរណ៍មួយ ដែលច្បាប់សន្មតថា ជនជាប់ចោទជាជនស្លូតត្រង់ គឺគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន (ក្នុងគោលការណ៍កំណត់ថាមានតែក្នុងករណីលើកលែង និងអនុលោមតាមលក្ខខណ្ឌជាក់លាក់ ដែលជនជាប់ចោទអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន)។[cxvi] យោងតាមរបាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានឲ្យដឹងថា សេចក្តីសម្រេចនៃការឃុំខ្លួនបណ្តោះអាសន្នរបស់តុលាការមានចំនួន ១៧៦ករណី ក្នុងចំណោម ១៩៩ករណី។[cxvii] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរាយការណ៍បន្តថា សេចក្តីសម្រេចភាគច្រើន គឺបានសន្មតថា ជនជាប់ចោទមានទោស នៅមុនពេលប្រកាសសាលក្រម។[cxviii]

### ២.៦. តើជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីភ្លាមៗ ឬអាចប្រាស្រ័យទាក់ទងជាមួយមេធាវីដោយទៀងទាត់ ឬសិទ្ធិទទួលការតំណាងដោយមេធាវីនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ ឬមេធាវីត្រូវបានតែងតាំងចំពោះជនជាប់ចោទពុំមានលទ្ធភាពបង់ថ្លៃសេវា? តើជនជាប់ចោទត្រូវបានផ្តល់ព័ត៌មានពីសិទ្ធិទាំងនេះ ប្រសិនបើពួកគេគ្មានជំនួយផ្នែកច្បាប់?

ប្រភពទីមួយនៃជំនួយផ្នែកច្បាប់ គឺរដ្ឋធម្មនុញ្ញ ដែលបានចែងថា "គ្រប់ពលរដ្ឋទាំងអស់មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"។[cxix] ប្រភពទីពីរ គឺក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងពីដំណាក់កាលនីមួយៗ និងស្ថានភាពដែលជនជាប់ចោទត្រូវបានផ្តល់ព័ត៌មានពីសិទ្ធិក្នុងការទទួលបានជំនួយផ្នែកច្បាប់ និងតម្រូវការឲ្យមានវត្តមានជាមុនរបស់មេធាវី មុននឹងចំណាត់ការណាមួយធ្វើឡើងដោយមន្ត្រីយុត្តិធម៌ (នគរបាល ព្រះរាជអាជ្ញា និងចៅក្រម)។ មន្ត្រីយុត្តិធម៌តម្រូវ[cxx] ឲ្យផ្តល់ព័ត៌មានទៅជនជាប់ចោទ អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់។[cxxi] ទោះបីជា ជនជាប់សង្ស័យមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ក៏សិទ្ធិនេះទទួលបានក្រោយរយៈពេល ២៤ម៉ោង បន្ទាប់ពីការឃុំឃាំងដោយមន្ត្រីនគរបាល។[cxxii] ទោះបីជា ច្បាប់បានផ្តល់សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានឲ្យដឹងថា ពុំមានជនជាប់ចោទណាម្នាក់ទទួលបានជំនួយផ្នែកច្បាប់ភ្លាមៗក្រោយពេលចាប់ខ្លួន និងពុំមានបន្ទប់ឯកជនដែលផ្តល់ដល់មេធាវីក្នុងការជួបប្រាស្រ័យជាមួយកូនក្តីឡើយ។[cxxiii] ចំណែក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្ហាញថា សវនាការចំនួន ៦៤ ក្នុងចំណោមសវនាការ ១៩៩ ពុំមានជំនួយពីមេធាវីទេ ចំណែកឯសវនាការលើសំណុំរឿងឧក្រិដ្ឋចំនួន ៥ ក្នុងចំណោម ១០៥ ក៏ពុំមានវត្តមានមេធាវីដែរ ទោះបីជាច្បាប់បានតម្រូវដាច់ខាតឲ្យមានអ្នកតំណាងផ្លូវច្បាប់។[cxxiv]

ប្រភពទីបីនៃសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ គឺច្បាប់ស្តីពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[cxxv] និងបទបញ្ជាផ្ទៃក្នុង។[cxxvi] ក្រោមបញ្ញត្តិនេះ មេធាវីគ្រប់រូបត្រូវចូលរួមផ្តល់ជំនួយផ្នែកច្បាប់។[cxxvii] បន្ថែមលើនេះ ជនក្រីក្រត្រូវទទួលបានសេវាជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ តាមរយៈមូលនិធិដែលបានមកពីវិភាគទាននៃសមាជិកនៃគណៈមេធាវី។[cxxviii] មេធាវីការពាររឿងក្តីប្រជាជនក្រីក្រ គឺទទួលបានសេវាពីមូលនិធិរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើនីតិវិធីជាក់លាក់ និងតម្លៃដែលបានកំណត់ក្នុង ១ឆ្នាំម្តង ដោយក្រុមប្រឹក្សាគណៈមេធាវី។ សំខាន់ជាងនេះ ករណីដែលមេធាវីពុំបានបំពេញកាតព្វកិច្ចឲ្យបានពេញលេញ គឺអាចប្រឈមនឹងការដាក់វិន័យ។

ការស្រាវជ្រាវមួយនៅឆ្នាំ២០០៦ បានទទួលស្គាល់ថា សេវាជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ គឺផ្តល់ទាំងស្រុងដោយមេធាវីដែលធ្វើការនៅអង្គការក្រៅរដ្ឋាភិបាល លើកលែងតែសេវាផ្តល់ដោយគណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជា និងការការពារក្តីដោយមិនយកប្រាក់កម្រៃពីមេធាវីឯកជន។[cxxix] ការស្ទាបស្ទង់មតិមួយនៅចុងឆ្នាំ ២០០៦ បានបង្ហាញថា ប្រជាជនកម្ពុជាមានកម្រិតយល់ដឹងតិចតួចអំពីការទទួលបានសេវាជំនួយផ្នែកច្បាប់ និងពីកន្លែងដែលពួកគាត់អាចទទួលបានសេវានេះ។ ជាទូទៅ ប្រជាពលរដ្ឋទទួលបានព័ត៌មាននេះពីអាជ្ញាធរមូលដ្ឋាន។ ផ្ទុយទៅវិញ កូនក្តីមួយចំនួនមានផលវិបាកផ្នែកហិរញ្ញវត្ថុក្នុងការធ្វើដំណើរទៅកាន់ការិយាល័យផ្តល់ជំនួយផ្នែកច្បាប់ ដើម្បីធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយមេធាវី។ ជាងនេះទៀត កម្រិតយល់ដឹងនៃច្បាប់ បានរារាំងដល់ការផ្តល់ជំនួយផ្នែកច្បាប់ឲ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព។ កង្វះធនធានមនុស្ស (មេធាវី) ថវិកា និងហិរញ្ញវត្ថុសម្រាប់ដោះស្រាយប្រាក់បៀវត្សរ៍ និងការចំណាយលើការស៊ើបអង្កេត ព្រមទាំង ការចំណាយនានា គ្រឿងបរិក្ខាអេឡិចត្រូនិក និងអត្ថបទច្បាប់ដែលមានជាធរមាន។[cxxx] ការជួបវិបត្តិសេដ្ឋកិច្ច បានធ្វើឲ្យអង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងប្រឈមនឹងការបិទទ្វារ ឬក៏ត្រូវធ្វើការផ្លាស់ប្តូរទីតាំងការិយាល័យ ពីព្រោះពុំមានលទ្ធភាពក្នុងការបង់ថ្លៃជួលទីតាំង។[cxxxi] ការប្តូរទីតាំងថ្មីធ្វើឲ្យមានការលំបាក ដល់កូនក្តីដែលមានជីវភាពក្រខ្សត់ ដើម្បីទទួលបានជំនួយផ្នែកច្បាប់។ ការពុំមានមូលនិធិគ្រប់គ្រាន់ គឺជាឧបសគ្គមួយ ដែលធ្វើឲ្យសេវាជំនួយផ្នែកច្បាប់ពុំមានប្រសិទ្ធិភាព ព្រោះបានបង្ខំឲ្យមេធាវីស្វែងរកប្រាក់ចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ជីវភាព និងគ្រួសារខ្លួន ជាជាងការផ្តោតសំខាន់លើការងារការពារផលប្រយោជន៍សាធារណៈ។ សមត្ថភាព និងវិជ្ជាជីវៈរបស់មេធាវី ក៏ជាបញ្ហាចោទដែលធ្វើឲ្យការផ្តល់សេវាជំនួយផ្នែកច្បាប់ ដែលគ្មានប្រសិទ្ធិ

ភាព។

**២.៧. តើច្បាប់ធានាចំពោះជនជាប់ចោទនូវសិទ្ធិទទួលបានការផ្តល់ព័ត៌មាន អំពីការចោទប្រកាន់ នៅក្នុងពេលសមស្រប មានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការពារខ្លួន និងទំនាក់ទំនងជាមួយមេធាវី?**

ជនជាប់ចោទមានសិទ្ធិទទួលបានការផ្តល់ព័ត៌មានជាមុន អំពីបទចោទប្រកាន់ជាក់លាក់លើខ្លួន នៅក្នុងភាសាដែលអាចយល់បាន។[cxxxii] មេធាវីការពារក្តីឲ្យជនជាប់ចោទ មានរយៈពេលតែ ៥ថ្ងៃ ក្នុងការពិនិត្យមើលសំណុំរឿងមុនចូលឆ្លើយបំភ្លឺនៅជំណាក់កាលថៅក្រមស៊ើបសួរ[cxxxiii] ទោះបីជាមានការប្បញ្ញត្តិថា ជនជាប់ចោទមានពេលវេលាសមរម្យក្នុងការត្រៀមការពារខ្លួន។[cxxxiv] មាត្រា ៤៥៧ និង មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីពេលវេលាសមស្របដែលជនជាប់ចោទត្រូវការត្រៀមការពារខ្លួន ហើយពេលវេលានេះអាស្រ័យតាមទីកន្លែងរបស់ជនជាប់ចោទ។[cxxxv] បទប្បញ្ញត្តិផ្សេងទៀតទាក់ទងនឹងពេលវេលាសមស្របក្នុងការត្រៀមការពារខ្លួន គឺមានក្នុង មាត្រា ៣០៤ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) មាត្រា៣១៩ (ការពិនិត្យមើលសំណុំរឿង)[cxxxvi] មាត្រា ៣២២ (វិធានទាក់ទងនឹងភាគីដែលមានវត្តមាននៅក្នុងសវនាការ) មាត្រា ៤២៨ (ការដាក់សំណុំរឿងជូនពិនិត្យ) និងមាត្រា ៤២៩ (ការពន្យាររយៈពេលនៃការសរសេរសារណា)។

នៅក្នុងការអនុវត្តន៍ជាក់ស្តែង ដូចមាន នៅក្នុងរបាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្ស ជនជាប់ចោទស្ទើរតែទាំងអស់ទទួលបានព័ត៌មានអំពីបទចោទប្រកាន់លើពួកគេ។[cxxxvii] ទោះបីជាយ៉ាងណា មានចំណោទថាតើជនជាប់-ចោទមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមការពារខ្លួន នៅពេលពួកគេ ឬមេធាវីពួកគេទទួលបានការជូនដំណឹងក្នុងរយៈខ្លីមុនថ្ងៃសវនាការ (ជាពិសេស សវនាការលើអង្គហេតុសេចក្តី)។[cxxxviii] មួយវិញទៀត ការធានានូវការប្រាស្រ័យទាក់ទងដោយសេរី រវាងជនជាប់ចោទ និងមេធាវី (ដោយមិនមានការស្តាប់ ឬថតសម្លេង) មានចែងក្នុងមាត្រា ១៤៩ (សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ)។

**២.៨. តើច្បាប់បានធានាដល់ជនជាប់ចោទនូវសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ការជំនុំជម្រះចំពោះមុខជនជាប់ចោទ និងការការពារខ្លួនដោយខ្លួនឯង ឬដោយមេធាវី (ការសួរដេញដោលសាក្សី និងការពិនិត្យភស្តុតាង)?**

ទោះបីជា ពុំមានវាក្យស័ព្ទច្បាប់អំពី "ការជំនុំជម្រះដោយគ្មានការពន្យារពេល" ក៏ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិឲ្យសភាស៊ើបសួរ ក្នុងការធានាថា ដំណើរការនីតិវិធីពុំមានការពន្យារពេល។[cxxxix] ការហាមឃាត់ការពន្យារពេលមានបទប្បញ្ញត្តិមួយចំនួនបានប្រើពាក្យ ដូចជា "...ដោយគ្មានការពន្យារពេល" "...ការពន្យារពេលដោយមិនចាំបាច់" ឬ "...ដោយបន្ទាន់"។ នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ក្រមនីតិវិធីព្រហ្មទណ្ឌបានតម្រូវឲ្យប្រកាសសាលក្រម ក្នុងអំឡុងពេល ២សប្តាហ៍ នៅចំពោះមុខជនជាប់ចោទ។[cxl] ក្នុងករណីដែលព្រះរាជអាជ្ញាបញ្ជាឲ្យមានការស៊ើបអង្កេត ជាជាងដំណើរការនីតិវិធីបង្ហាញខ្លួនភ្លាម ករណីនេះពុំបានកំណត់ពីពេលវេលាជាក់លាក់ទេ គ្រាន់តែចែងថា ការប្រកាសសាលក្រម គឺធ្វើនៅ "ក្នុងកំឡុងពេលសមរម្យ"។[cxli]

បទប្បញ្ញត្តិស្តីពីការឃុំខ្លួនរង់ចាំសវនាការ ឬការឃុំខ្លួនបណ្តោះអាសន្ន ក៏ធានាពីគោលការណ៍ជំនុំជម្រះដោយ

គ្មានការពន្យារពេល។ រយៈពេលនៃការពន្យាពេលឃុំខ្លួន ត្រូវបានបញ្ជាក់យ៉ាងជាក់លាក់យោងតាមប្រភេទនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ។[cxlii] មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់នូវរយៈពេលឃុំខ្លួនបន្ថែមចំនួន ៤ខែ ក្នុងការបញ្ចប់ការស៊ើបសួររបស់ខ្លួន។ មជ្ឈមណ្ឌលសិទ្ធិមនុស្ស លើកឡើងថា មានករណីចំនួន ៨ ក្នុងចំណោម ១៩៩ មានការរំលោភលើដំណើរការនីតិវិធី។ សំណុំរឿងភាគច្រើន ដែលបានរាយការណ៍ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស បានបង្ហាញថា ការឃុំខ្លួនរង់ចាំសវនាការ គឺលើសពីរយៈពេលនៃការផ្តន្ទាទោស អាចពី ១សប្តាហ៍ ដល់ ១ឆ្នាំ ឬរហូតដល់ ២ឆ្នាំ។

សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលសាក្សី និងពិនិត្យភស្តុតាងប្រឆាំងខ្លួន ក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ព្រះរាជអាជ្ញាជាអ្នកធ្វើការកោះហៅសាក្សី ប៉ុន្តែ មេធាវីការពារក្តីក៏អាចដាក់ជូនឈ្មោះសាក្សី ដែលមិនបានកោះហៅដោយព្រះរាជអាជ្ញាផងដែរ ដោយស្នើសុំឲ្យតុលាការស្តាប់សក្ខីកម្មរបស់ពួកគេក្នុងនាមជាសាក្សី។[cxliii] ក្នុងករណីដែលសវនាការធ្វើឡើងដោយគ្មានវត្តមានជនជាប់ចោទ (សវនាការកំបាំងមុខ) ក្រមនេះបាន អនុញ្ញាតឲ្យជនជាប់ចោទមានសិទ្ធិប្តឹងជំទាស់នឹងសាលក្រមកំបាំងមុខ។[cxliv]

ជាក់ស្តែង កម្មវិធីឃ្លាំមើលតុលាការមួយបានបង្ហាញថា ជនជាប់ចោទគ្រប់រូបត្រូវបានផ្តល់ឱកាសឲ្យដាក់បង្ហាញភស្តុតាង និងពិនិត្យភស្តុតាងប្រឆាំងខ្លួន។ របាយការណ៍ឃ្លាំមើលតុលាការនេះ បានកត់សម្គាល់ថា សាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការ គឺនៅមុនពេលខ្លួនផ្តល់សក្ខីកម្ម។

## ២.៩. តើច្បាប់បានផ្តល់សិទ្ធិប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់តាមនីតិវិធីច្បាប់ដែរឬទេ?

ការប្តឹងឧបាស្រ័យទៅសាលាឧទ្ធរណ៍អាចធ្វើឡើងដោយមានចិរវេលាកំណត់[cxlv] ចំណែកទៅតុលាការកំពូល[cxlvi] គឺយោងតាមអជ្ញាយុកាលនៃបណ្តឹងឧទ្ធរណ៍។[cxlvii] ក្នុងករណីមានការជំទាស់នឹងសាលក្រមស្ពាពររបស់តុលាការ ដែលមានអានុភាពជាអជ្ញាអស់ជំនុំ ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានអនុញ្ញាតឲ្យមានបណ្តឹងសើរើទៅកាន់តុលាការកំពូល (សភាពេញអង្គ)។[cxlviii] ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី មិនត្រឹមតែផ្តល់លទ្ធភាពក្នុងការប្តឹងឧបាស្រ័យនឹងសាលក្រមរបស់ចៅក្រមជំនុំជម្រះទេ ថែមទាំងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដូចជា ការឃុំខ្លួនបណ្តោះអាសន្ន។[cxlix]

ការប្រើប្រាស់សិទ្ធិប្តឹងឧបាស្រ័យ នៅតែជួបឧបសគ្គ។ នៅខែកុម្ភៈ ឆ្នាំ២០១០ អង្គការលីកាដូ (LICADHO) បានចេញផ្សាយអត្ថបទសង្ខេបមួយ អំពីឧបសគ្គក្នុងការប្តឹងឧបាស្រ័យ រួមមាន មធ្យោបាយដឹកជញ្ជូនរបស់ពន្ធនាគារនានាទៅកាន់សាលាឧទ្ធរណ៍ កង្វះខាតថវិការចំណាយលើការធ្វើដំណើរ ដូចជា ថ្លៃសាំង កង្វះបុគ្គលិក ទីកន្លែងស្នាក់អាស្រ័យ និងការចំណាយផ្សេងៗសម្រាប់បុគ្គលិក។ល។[cl] ជាលទ្ធផល អ្នកទោសនៅក្នុងពន្ធនាគារខេត្តចំនួន៧ ចំនួន ៥៤០នាក់ ដែលរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍ កំពុងប្រឈមនឹងការខកខានមិនបានចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន "សវនាការឧទ្ធរណ៍កំបាំងមុខ"។[cli] អត្ថបទនេះ[clii] បានបន្តថា ឧបសគ្គទាំងនេះ បានធ្វើឲ្យការការពារក្តីមិនមានប្រសិទ្ធិភាព និង/ឬ មិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ត្រៀមការពារខ្លួនដោយហេតុថា ជនជាប់ចោទអាចត្រូវបញ្ជូនទៅកាន់សាលាឧទ្ធរណ៍នៅថ្ងៃសវនាការ។[cliii]

**២.១០. តើច្បាប់បានហាមឃាត់ការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំ "ជាភស្តុតាង" និងបានធានានូវសិទ្ធិជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយដែរឬទេ?**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានហាមឃាត់នូវការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំ "ជាភស្តុតាង"។[cliv] បន្ថែមលើនេះ បទប្បញ្ញត្តិអំពីវិធាននៃភស្តុតាង ត្រូវបានរួមបញ្ចូលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី (ឆ្នាំ២០០៧) ដោយសន្មតថា រាល់ភស្តុតាងទាំងអស់អាចទទួលយកបាន ហើយចៅក្រមជំនុំជម្រះនឹងថ្លឹងថ្លែងអំពីតម្លៃភស្តុតាង ដោយផ្អែកលើជំនឿស្មោះត្រង់ និងពិតប្រាកដរបស់ខ្លួន។[clv] ប៉ុន្តែជាក់ស្តែង ភស្តុតាងជាក់លាក់មួយចំនួន គ្មានតម្លៃជាភស្តុតាង ឬមិនអាចទទួលយកបានឡើយ រួមមាន ភស្តុតាងទទួលបានតាមរយៈការបង្ខិតបង្ខំរាងកាយ ឬផ្លូវចិត្ត និងភស្តុតាងទទួលបានពីការប្រាស្រ័យទាក់ទង រវាងជនជាប់ចោទ និងមេធាវី។[clvi] ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយនៅគ្រប់ដំណាក់ ទាំងកាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ[clvii] ប៉ុន្តែនៅការអនុវត្តន៍នៅតែជួបបញ្ហាប្រឈម។ ឧទាហរណ៍ របាយការណ៍ឃ្លាំមើលតុលាការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាឆ្នាំ២០១០ បានញ៉ាំងឲ្យឃើញពីសញ្ញាណនៃការទាញយកចម្លើយសារភាពដោយការបង្ខិតបង្ខំ (គំរាមកំហែង) ឬការធ្វើទារុណកម្ម (ការប្រើកម្លាំង)។[clviii] អង្គការក្រៅរដ្ឋាភិបាល ក៏បានឲ្យដឹងថា ទារុណកម្ម គឺជាទម្លាប់មួយដែលមន្ត្រីប៉ូលីសកំពុងបន្តអនុវត្ត ព្រោះពួកគេខ្វះនូវការបណ្តុះបណ្តាលត្រឹមត្រូវ ខ្វះមធ្យោបាយក្នុងការស៊ើបអង្កេត និងភាពនិទណ្ឌភាព។[clix]

**២.១១. តើច្បាប់បានហាមឃាត់ចំពោះការជំនុំជម្រះ ឬផ្តន្ទាទោសលើកទីពីរចំពោះបទល្មើស ដែលតុលាការបានសម្រេចជាស្ថាពរថា មានទោស ឬគ្មានទោស ដែរឬទេ?**

ក្រមនីតិវិធីព្រហ្មទណ្ឌ ពិតជាបានហាមឃាត់ចំពោះការជំនុំជម្រះ ឬផ្តន្ទាទោសលើកទីពីរចំពោះបទល្មើស ដែលតុលាការបានសម្រេចជាស្ថាពរថា មានទោស ឬគ្មានទោស (គឺជា អាជ្ញាអស់ជំនុំ)[clx] ករណីលើកលែង បណ្តឹងសើរើ ត្រូវបានអនុញ្ញាតឲ្យមានការជំនុំជម្រះឡើងវិញ។[clxi] ចំណែកគោលការណ៍ជាទូទៅនៃ ការអនុគ្រោះទោស និងការលើកលែងទោស ពុំមែនជាឧបសគ្គក្នុងការជំនុំជម្រះជនណាម្នាក់នោះឡើយ ជាពិសេស បទឧក្រិដ្ឋធ្ងន់ធ្ងរ (បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋប្រល័យពូជសាសន៍)។[clxii]

**២.១២. តើច្បាប់បានផ្តល់សិទ្ធិទាមទារសំណងឲ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាព ចំពោះការរំលោភបំពានសិទ្ធិជាមូលដ្ឋានដែរឬទេ?**

ជាទូទៅ សិទ្ធិ និងសេរីភាពនៃប្រជាពលរដ្ឋខ្មែរត្រូវបានការពារដោយអំណាចតុលាការ។[clxiii] រដ្ឋធម្មនុញ្ញកម្ពុជា និងក្រមព្រហ្មទណ្ឌ បានផ្តល់សិទ្ធិទាមទារសំណងនៅតុលាការមានសមត្ថកិច្ច (តុលាការគ្រប់ជាន់ថ្នាក់) ចំពោះបណ្តឹងប្រឆាំងនឹងរាជការសាធារណៈ។[clxiv] ជាងនេះទៀត ការរំលោភបំពានសិទ្ធិជាមូលដ្ឋានដោយបុគ្គលឯកជន ត្រូវដោះស្រាយ និងផ្តល់សំណងដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។[clxv] សំណងពីរប្រភេទត្រូវបានកំណត់ ចំពោះការរំលោភបំពានសិទ្ធិមូលដ្ឋាន ដោយបុគ្គលឯកជន ឬរាជការសាធារណៈ គឺ ការដាក់ពន្ធនាគារ (ទោសអតិបរមា ជាប់ពន្ធនាគារអស់មួយជីវិត) និង/ឬ ការផាកពិន័យ។[clxvi] សំណងការខូចខាតដោយអំពើរំលោភបំពានសិទ្ធិ គឺធ្វើឡើងក្នុងគោលបំណងស្តារឡើងវិញនូវការខូចខាត ឬការបំផ្លិចបំផ្លាញ ដោយឲ្យមានលក្ខណៈសមាមាត្រទៅនឹងស្ថានភាពដើម។[clxvii]

នៅក្នុងការអនុវត្តន៍ជាក់ស្តែងត្រូវបានរាយការណ៍ថា សំណាងមិនត្រូវបានអនុវត្តឲ្យមានប្រសិទ្ធិភាពទេ ដោយអ្នកបំពានសិទ្ធិមនុស្សមិនត្រូវបានផ្តន្ទាទោស។[clxviii] ជនរងគ្រោះ ឬក្រុមគ្រួសារ ស្ថិតក្រោមសំពាធគំរាមកំហែងមិនឲ្យប្តឹងទៅតុលាការ និងបញ្ចុះបញ្ចូល ឬបង្ខំឲ្យទទួលយកសំណាងជាលុយកាក់ជំនួសការប្តឹងផ្តល់។[clxix] ជារឿយៗ អាជ្ញាធរមូលដ្ឋានតែងតែស្វែងរកដំណោះស្រាយជូនជនរងគ្រោះ ដោយឲ្យទទួលសំណាងពីជនល្មើស (ជាពិសេស ជនរងគ្រោះពីអំពើរំលោភសេពសន្ថវៈ ឬបៀតបៀនកេរ្តិ៍កេរ) ដែលជាជម្រើសជំនួសការប្តឹងចោទប្រកាន់បទព្រហ្មទណ្ឌ។ សិទ្ធិប្តឹងទាមទារសំណាងរដ្ឋប្បវេណី ក៏ត្រូវបានរារាំង ដោយការតម្រូវឲ្យបង់ប្រាក់ប្រដាប់ក្តី និងបង់ពន្ធលើពាក្យបណ្តឹង។ ការទាមទារសំណាង ក៏អាចធ្វើបាននៅក្រៅប្រព័ន្ធពីនីតិវិធីតុលាការ ដូចជា បណ្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល[clxx] និងគណៈកម្មការសុរិយោដី។[clxxi]

## ៣. ដំណើរការអនុម័ត និងការអនុវត្តន៍ច្បាប់ត្រូវបានបើកចំហជាសាធារណៈ មានលក្ខណៈយុត្តិធម៌ មានប្រសិទ្ធិភាព និងស្មើភាពគ្នាដែរឬទេ?

### ៣.១. តើកិច្ចប្រជុំនីតិកម្មត្រូវបានជូនដំណឹងក្នុងពេលវេលាសមស្រប និងបើកចំហជាសាធារណៈដែរឬទេ?

ដំណើរការនីតិកម្ម ឬសម័យប្រជុំត្រូវតែធ្វើឡើងជាសាធារណៈ លើកលែងតែមានការស្នើសុំផ្សេងទៀត។[clxxii] សម័យប្រជុំត្រូវបានធ្វើ ២ដង ក្នុង ១ឆ្នាំ ដែលសម័យប្រជុំនីមួយៗមានរយៈពេល ៣ខែ ចំណែកឯសម័យប្រជុំវិសាមញ្ញ ក៏អាចធ្វើបានដែរ។ របៀបវារៈសម្រាប់សម័យប្រជុំ គឺស្នើឡើងដោយអគ្គលេខាធិការដ្ឋាននៃសភាទាំងពីរ និងជូនដំណឹងជាសាធារណៈ។[clxxiii] ប៉ុន្មានឆ្នាំកន្លងមក មានការផ្សាយបន្តផ្ទាល់ពីទូរទស្សន៍ជាតិ អំពីសម័យប្រជុំ ឬកិច្ចពិភាក្សាច្បាប់នៅសភាទាំងពីរ (រដ្ឋសភា និង ព្រឹទ្ធសភា)។ ចំពោះព័ត៌មានពីកំណត់ត្រាជាលាយលក្ខណ៍អក្សរ ស្តីពីសម័យប្រជុំនីតិកម្ម គឺអាចរកបានតិចតួចបំផុត ដែលនាំឲ្យមានចំណោទ ថាតើកំណត់ត្រា ឬកំណត់សេចក្តីត្រូវបានចែកផ្សាយជាសារធារណៈឬទេ។

### ៣.២. តើសេចក្តីព្រាងច្បាប់ និងប្រតិចារិក ឬកំណត់ហេតុនៃសម័យប្រជុំនីតិកម្ម ត្រូវបានចែកជូនដល់សាធារណៈក្នុងពេលវេលាមួយសមស្របដែរឬទេ?

កាលពីប៉ុន្មានឆ្នាំមុន សេចក្តីព្រាងច្បាប់ត្រូវបានចាត់ទុកជាឯកសារសម្ងាត់។ ឯកសារពង្រាងនេះ ចែកចាយតែក្នុងចំណោមស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធក្នុងដំណើរការពិគ្រោះយោបល់ជាសាធារណៈប៉ុណ្ណោះ។ ទើបតែថ្មីៗនេះ សេចក្តីព្រាងច្បាប់មួយចំនួនបានផ្សាយទូលាយដល់មជ្ឈដ្ឋានសិក្សា (សិស្សនិស្សិត)។[clxxiv] ការចូលរួមផ្តល់មតិយោបល់យ៉ាងផុសផុល រវាងសង្គមស៊ីវិល និងរដ្ឋាភិបាល ក្នុងការអនុម័តច្បាប់ ស្តីពីបាតុកម្មដោយសន្តិវិធី[clxxv] ត្រូវបានសាធារណជនសាទរជាខ្លាំង ប៉ុន្តែចំពោះច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីអង្គការ និងសមាគម ពុំត្រូវបានបើកឱកាសទូលាយឲ្យមានកាផ្តល់មតិយោបល់ទេ និងព័ត៌មានតិចតួចប៉ុណ្ណោះផ្តល់ជូនសាធារណជន ជាពិសេស ក្រុមសង្គមស៊ីវិល។[clxxvi] រដ្ឋាភិបាលបានផ្លាស់ប្តូរជំហររបស់ខ្លួន ដោយឲ្យមានការចូលរួម និងទទួលយកអនុសាសន៍របស់អង្គការសង្គមស៊ីវិលមកពិចារណា។[clxxvii] បញ្ហាកង្វះការដេញដោល និងការជជែកពិភាក្សានៅសភា ត្រូវបានលើកជាកង្វល់ចម្បង ជាពិសេស ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី នៅខែតុលា ឆ្នាំ២០០៩ ច្បាប់ស្តីពីអស្សាមិករណ៍នៅខែកុម្ភៈ នៅឆ្នាំ២០១០ និងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៅ ខែមីនា ឆ្នាំ២០១០។

### ៣.៣. តើសិទ្ធិប្តឹងទៅតុលាការត្រូវបានកម្រិតជាក់លាក់ដោយរបៀបណា ក្នុងការមិនឲ្យរើសអើង និងមិនរិតត្បិតពេក?

សិទ្ធិប្តឹងតាមផ្លូវតុលាការត្រូវបានបញ្ជាក់យ៉ាងច្បាស់ ជាពិសេស នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[clxxviii] នៅក្នុងក្រមព្រហ្មទណ្ឌថ្មី (២០០៩) បានអនុញ្ញាតឲ្យសមាគមមួយចំនួនអាចជួយជនរងគ្រោះ ក្នុងការដាក់ពាក្យបណ្តឹង។[clxxix] លើសពីនេះ ជនរងគ្រោះអាចត្រូវបានតំណាងដោយទាយាទរបស់ខ្លួន (ក្នុងករណីដែលទទួលមរណភាព) ឬអ្នកតំណាងស្របច្បាប់ (ក្នុងករណីជាអនីតិជន ឬជនស្ថិតក្រោមអាណាព្យាបាល) និងអាចប្តឹងទាមទារសំណងរដ្ឋប្បវេណីភ្ជាប់ជាមួយបណ្តឹងព្រហ្មទណ្ឌ ដែលធ្វើឡើងដោយព្រះរាជអាជ្ញា។[clxxx] រដ្ឋធម្មនុញ្ញ ក៏បានកំណត់ពីសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រជាពលរដ្ឋអាចប្រើប្រាស់សិទ្ធិនេះ តាមរយៈអ្នកតំណាងរាស្ត្រ និងតុលាការកំពូល ស្នើសុំឲ្យពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់ និងបទបញ្ញាផ្សេងៗអនុវត្តដោយស្ថាប័ននីតិប្រតិបត្តិ ដែលប៉ះពាល់ដល់សិទ្ធិមានចែងក្នុងរដ្ឋធម្មនុញ្ញ។[clxxxi] បុគ្គលគ្រប់រូប អ្នកតំណាងស្របច្បាប់ បណ្តុំមនុស្ស អង្គការ ឬសមាគម ក៏មានសិទ្ធិប្តឹងទៅកាន់គណៈកម្មាធិការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង។[clxxxii]

### ៣.៤. តើសវនាការ និងសាលក្រមតុលាការ ធ្វើជាសាធារណៈ និងបានប្រគល់ជូនគូភាគីដែលមានផលប្រយោជន៍ភ្លាមៗដែរឬទេ?

សវនាការជំនុំជម្រះក្តីត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែករណីដែលពាក់ព័ន្ធនឹងសីលធម៌សង្គម សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬជីវភាពឯកជនរបស់បុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តី[clxxxiii] ចំណែកការប្រកាសសាលក្រមត្រូវធ្វើឡើងជាសាធារណៈ[clxxxiv] ដែលសេចក្តីសម្រេចត្រូវបានប្រកាសដោយប្រធានចៅក្រម។[clxxxv] ការឃ្លាំមើលតុលាការថ្មីៗនេះ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្ហាញថា ក្នុងចំណោម ១៩៩សវនាការ សាធារណជនមិនត្រូវបានហាមឃាត់មិនឲ្យចូលរួមនោះទេ ក៏ប៉ុន្តែសេចក្តីជូនដំណឹងពីកាលវិភាគសវនាការ នៅលើក្តារផ្តល់ព័ត៌មានជាសាធារណៈមានចំនួនតែ ៥ករណី ប៉ុណ្ណោះ។[clxxxvi] នាពេលថ្មីៗនេះ តុលាការបានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ជាពិសេស សាលាដំបូងរាជធានីភ្នំពេញ និងតុលាការកំពូល បានផ្តល់ព័ត៌មានពីកាលវិភាគសវនាការជាសាធារណៈលើក្តារព័ត៌មាន និងគេហទំព័ររបស់ខ្លួន។ មួយវិញទៀត ការប្រកាសសាលក្រម ក៏តម្រូវឲ្យផ្តល់ព័ត៌មានទៅដល់គូភាគីនានាផងដែរ។[clxxxvii] សូមរកមើលព័ត៌មានពីការផ្សព្វផ្សាយនៃសេចក្តីសម្រេចនៅផ្នែក "ទិដ្ឋភាពទូទៅ" ចំនុចទី ៤ "ការបកស្រាយ និងការអនុវត្តន៍នីតិរដ្ឋ" ជាពិសេស "តារាងរចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធយុត្តិធម៌"។

### ៣.៥. បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងតើមានសិទ្ធិទទួលបានការការពារពីច្បាប់ស្មើៗគ្នាដោយមិនមានការរើសអើងដែរឬទេ?

ច្បាប់ផ្តល់នូវការការពារស្មើៗគ្នា[clxxxviii] ប៉ុន្តែនៅក្នុងការអនុវត្តន៍ជាក់ស្តែងមានការលើកឡើងថា ច្បាប់ការពារតែអ្នកមានទ្រព្យសម្បត្តិ ឬមានអំណាច។[clxxxix] ជាពិសេស បញ្ហាដីធ្លី ដែលកើតឡើងពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងគម្រោងអភិវឌ្ឍន៍ដទៃទៀត[cxc] គឺបណ្តាលឲ្យមានការជម្លៀសដោយបង្ខំ[cxci] និងរឹបអូសយកដីធ្លី។[cxcii] អគ្គស្នងការការពារសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានលើកពីបញ្ហាការការពារដោយស្មើភាព ដូចជា ករណីពាក់ព័ន្ធនឹងព្រះសង្ឃខ្មែរក្រោម ករណីអ្នកប្រឆាំងនឹងរដ្ឋាភិបាល[cxciii] ករណីការទទួលប្រាក់កម្រៃ និងការលើកកម្ពស់និយោជិតស្ត្រី[cxciv] ករណីឃឹតយ៉ាវ

ក្នុងការផ្តល់វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីធ្លីដល់ក្រុមជនជាតិដើមភាគតិច បើទោះជាមាន ភស្តុតាងបញ្ជាក់ពីការកាន់កាប់ដោយស្របច្បាប់។ល។[cxcv]

**៣.៦. តើបុគ្គលគ្រប់រូបអាចស្នើសុំជំនួយពីស្ថាប័នយុត្តិធម៌ដោយស្មើភាព មានប្រសិទ្ធិភាព និងមិនមានគំនៀបយកកម្រៃ ដោយមិនត្រឹមត្រូវ ឬឧបសគ្គផ្នែករដ្ឋបាលផ្សេងៗដោយបំពានដែរឬទេ?**

ជនរងគ្រោះនៅក្នុងករណីព្រហ្មទណ្ឌ គឺមិនតម្រូវឲ្យបង់ប្រាក់កម្រៃអ្វីឡើយ គឺជាការទទួលខុសត្រូវរបស់រដ្ឋ[cxcvi] ប៉ុន្តែចំពោះករណីវិវាទរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីត្រូវបង់ដោយដើមចោទ ប្រសិនបើចុងចម្លើយចាញ់ក្តី ចុងចម្លើយជាអ្នកទទួលខុសត្រូវចំពោះការបង់ចំណាយលើរឿងក្តី (បង់សង់ឲ្យដើមចោទវិញនូវប្រាក់ប្រដាប់ក្តីដែលបានចំណាយរួច)។ ក្រៅពីប្រាក់ចំណាយលើដំណើរការក្តី ពន្ធលើពាក្យបណ្តឹងត្រូវបានគណនាដោយផ្អែកលើតម្លៃនៃកម្មវត្ថុបណ្តឹង។ ប្រាក់ប្រដាប់ក្តីអប្បបរមាគឺ ២៥ដុល្លាអាមេរិក (តម្លៃប្រហាក់ប្រហែល) និងអតិបរមា គឺ ៧០ដុល្លាអាមេរិក (តម្លៃប្រហាក់ប្រហែល)។[cxcvii] ការទារយក "កម្រៃបន្ថែម" ដោយមន្ត្រីស្ថាប័នតុលាការ នៅតែក្តីព្រួយបារម្ភ ព្រោះថា ដើម្បីគោលបំណងទ្រទ្រង់ប្រាក់បៀវត្សរ៍ទាបរបស់ខ្លួន។[cxcviii] របាយការណ៍មួយ បានបង្ហាញឲ្យដឹងថា ជនរងគ្រោះដោយការជួញដូរមនុស្សមិនអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីទាមទារសំណងពីអ្នកប្រព្រឹត្តល្មើសបានទេ ដោយមូលហេតុថា ថ្លៃចំណាយដែលកំណត់ដោយតុលាការខ្ពស់ពេក។[cxcix] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ក៏បានរាយការណ៍ពីកង្វះការទទួលបានជំនួយពីស្ថាប័នយុត្តិធម៌ ដោយមូលហេតុថ្លៃចំណាយ ដែលកំណត់ដោយតុលាការខ្ពស់ពេក ដូចជា បទរំលោភសេពសន្ថវៈ និងបទប្រទូសកេររភេទលើស្ត្រី។[cc]

**៣.៧. តើច្បាប់ត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាព យុត្តិធម៌ និងស្មើភាពគ្នាដែរឬទេ? តើបុគ្គលដែលស្វែងរកយុត្តិធម៌ត្រូវបានផ្តល់ជំនួយសមស្របដែរឬទេ?**

បញ្ហាស្តីពីភាពស្មើគ្នាចំពោះមុខច្បាប់ ត្រូវបានពិភាក្សានៅក្នុងសូចនាករ ២.ខ។ ការព្រួយបារម្ភពីការអនុវត្តន៍ច្បាប់ដោយមិនស្មើភាព ក៏ត្រូវបានលើកឡើងជាបញ្ហា ករណីដូចជា ការប្រមូលផ្តុំធ្វើបាតុកម្មជាសាធារណៈ ការផ្តល់ព័ត៌មានមិនពិត និងការបរិហាកេរ្តិ៍ ដែលការអនុវត្តន៍នេះអាស្រ័យលើការប្រកាន់និន្នាការ ឬទស្សនៈនយោបាយរបស់អ្នកធ្វើបាតុកម្ម។

**៣.៨. តើច្បាប់បានផ្តល់សិទ្ធិទាមទារសំណងចំពោះការខូចខាតឲ្យបានគ្រប់គ្រាន់ មានប្រសិទ្ធិភាព និងឆាប់រហ័សដល់ជនរងគ្រោះរងអំពើព្រហ្មទណ្ឌ ឬការរំលោភសិទ្ធិមនុស្សដែរឬទេ? តើជនរងគ្រោះទទួលបានព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការរំលោភបំពាន និងយន្តការផ្តល់សំណងចំពោះការខូចខាតដែរឬទេ?**

គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងនៃរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជា គណៈកម្មការសិទ្ធិមនុស្សរបស់ស្ថាប័ននីតិប្រតិបត្តិ ត្រូវបានផ្តល់អំណាចក្នុងការដឹកនាំការស៊ើបអង្កេតចំពោះករណីរំលោភបំពានសិទ្ធិមនុស្ស ក៏ប៉ុន្តែស្ថាប័ននេះមិន[6]អាចផ្តល់ការជួសជុលការខូចខាតដល់ជនរងគ្រោះដោយអំពើ

---

[6]កំណែចំពោះភាសាអង់គ្លេសៈពី enabled ទៅជា unable.

រំលោភបំពានសិទ្ធិមនុស្សឲ្យមានប្រសិទ្ធភាព និងឆាប់រហ័សទេ (ឧទាហរណ៍ ៖ ជនរងគ្រោះដោយការបណ្ដេញចេញពីដីធ្លី) ឬយកអ្នករំលោភបំពានសិទ្ធិមនុស្សមកទទួលខុសត្រូវចំពោះមុខច្បាប់។ ការលើកឡើងថា ស្ថាប័នទាំងនេះ ជាទូទៅអនុវត្តអណត្តិខ្លួនដោយពុំមានប្រសិទ្ធិភាព។[cci] ជនរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្ស ជារឿយៗ សុំជំនួយពីបណ្ដាអង្គការក្រៅរដ្ឋាភិបាល ឬបុគ្គលសំខាន់ៗក្នុងប្រទេស ដូចជា សមាជិករដ្ឋសភា នាយករដ្ឋមន្ត្រី ឬអ្នករាយការណ៍សិទ្ធិមនុស្សពិសេស...ជាដើម។[ccii]

**៣.៩. តើច្បាប់បានបញ្ញត្តិ និងព្រះរាជអាជ្ញា ចៅក្រម ឬមន្ត្រីយុត្តិធម៌ បានចាត់វិធានការ ដើម្បីជួយការពារដល់សាក្សី និងជនរងគ្រោះ (និងអ្នកតំណាង) ពីការជ្រៀតជ្រែកជីវភាពឯកជនដោយខុសច្បាប់ ព្រមទាំងធានាសុវត្ថិភាពសាក្សីក៏ដូចជា ក្រុមគ្រួសារ ពីការបំភិតបំភ័យ និងការសងសឹក នៅមុនពេល អំឡុងពេល និងក្រោយពេលដំណើរការជំនុំជម្រះ ឬដំណើរការរដ្ឋបាល ឬដំណើរការផ្សេងៗទៀត ដែលប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេដែរឬទេ?**

រហូតដល់ពេលនេះ គឺពុំមានយន្តការណា ក្រៅពីក្រមព្រហ្មទណ្ឌដែលផ្ដន្ទាទោសចំពោះអ្នកប្រព្រឹត្តបទល្មើសដែលបានបង្កបញ្ហាដល់សាក្សី ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី និងពុំមានយន្តការការពារសុវត្ថិភាព ដូចជាការបំភិតបំភ័យ ឬការសងសឹកចំពោះជនរងគ្រោះ សាក្សី និងគ្រួសាររបស់ពួកគេ មុនពេល និងក្រោយពេល ដំណើររឿងក្ដីប្រឆាំងនឹងអ្នកប្រព្រឹត្តបទល្មើស។ ការផ្ដន្ទាទោសចំពោះអ្នកប្រព្រឹត្តបទល្មើស គឺជាស្ពានទម្ងន់ទោស។[cciii]

## ៤. យុត្តិធម៌ត្រូវប្រកបដោយភាពមិនលំអៀង ឯករាជ្យ និងមានយុត្តិធម៌

ឧបសគ្គនៃឯករាជភាពនៃប្រព័ន្ធតុលាការ រួមមាន លទ្ធភាពក្នុងការដកហូតដំណែងចៅក្រម ដោយសារ ឥទ្ធិពលនយោបាយ និងប្រាក់បៀវត្សរ៍ទាប។ ចៅក្រមដែលមិនលំអៀង លុះត្រាតែចៅក្រមអាចធ្វើសេចក្ដីសម្រេច ដោយឈរលើមូលដ្ឋានភស្តុតាងតតាំងនៅក្នុងសវនាការ មិនមែនផ្អែកលើការគំរាមកំហែងសំណូក ភាពលំអៀង ផលប្រយោជន៍ហិរញ្ញវត្ថុឡើយ។ល។[cciv] តម្រូវការក្នុងការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាល[ccv] ហើយរដ្ឋាភិបាលបានផ្ដួចផ្ដើមការអភិវឌ្ឍន៍គោលនយោបាយឆ្ពោះទៅរកកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាពីសមត្ថភាពមន្ត្រីតុលាការ ភាពមិនលំអៀង និងឯករាជភាព នៃអំណាចតុលាការ និងស្ថាប័នយុត្តិធម៌។[ccvi]

**៤.១. តើព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការត្រូវបានតែងតាំង ដំឡើងដំណែង ចាត់ចែងដាក់វិន័យ និងការដកហូតដំណែង ធ្វើឡើងដោយឯករាជ្យ និងគណនេយ្យភាពឬទេ?**

ចៅក្រមមិនត្រូវបានដកហូតដំណែងទេ ប៉ុន្តែមានការដាក់វិន័យធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលស្ថាប័នមួយស្នើសុំទៅព្រះមហាក្សត្រក្នុងការតែងតាំង ផ្ទេរ និងដកហូតដំណែង ចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេស។[ccvii] របាយការណ៍ ខែតុលា ឆ្នាំ២០០៣ បានបង្ហាញថា មុនឆ្នាំ១៩៩៣ ចៅក្រម និងរដ្ឋអាជ្ញា ត្រូវបានតែងតាំងដោយបក្សកុំម្មុយនីស្ត និងមានចំណេះដឹងច្បាប់តិចតួចប៉ុណ្ណោះ។[ccviii] ទោះបីជា គុណវុឌ្ឍិ និងវគ្គបណ្ដុះបណ្ដាលរបស់ចៅក្រម មានលក្ខណៈល្អប្រសើរច្រើនក៏ដោយ ក៏នៅតែមានការចោទប្រកាន់ថា កត្តានយោបាយបានជះឥទ្ធិពលដល់

ការជ្រើសរើស និងតែងតាំងចៅក្រម។[ccix] ចៅក្រមមានសិទ្ធិតិចតួចក្នុងការត្រួតត្រាលើក្រឡាបញ្ជី ព្រោះថាក្រឡាបញ្ជីត្រូវបានតែងតាំងដោយក្រសួងយុត្តិធម៌។[ccx]

### ៤.២. តើព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការ ទទួលបានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ ធនធានគ្រប់គ្រាន់ និងប្រាក់បៀវត្សរ៍ធនល្មមនឹងទំនួលខុសត្រូវដែរឬទេ? តើថវិកាជាតិប៉ុន្មានភាគរយ ដែលបានបែងចែកសម្រាប់ស្ថាប័នតុលាការ និងស្ថាប័នយុត្តិធម៌ចម្បងៗដទៃទៀត?

ការបណ្ដុះបណ្ដាលមន្ត្រីតុលាការ ត្រូវបានផ្ដល់ដោយរដ្ឋាភិបាលដោយសហការជាមួយភ្នាក់ងារម្ចាស់ជំនួយជាច្រើន។[ccxi] ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីតុលាការ ទទួលបានប្រាក់បៀវត្សរ៍ស្មើនឹងមន្ត្រីរាជការដែរ។ ប្រភពមួយបានរាយការណ៍ថា ប្រាក់បៀវត្សរ៍របស់ចៅក្រម គឺចាប់ពី ៤០០ ទៅ ១,២០០ ដុល្លាអាមេរិក ក្នុង ១ខែ[ccxii] ឬពី ៤,៨០០ ទៅ ៨៤,០០០ ដុល្លាអាមេរិក ក្នុង ១ឆ្នាំ ដែលបង្ហាញពីគម្លាតយ៉ាងខ្លាំងរវាងប្រាក់បៀវត្សរ៍មន្ត្រីនៅតុលាការក្នុងស្រុក និងមន្ត្រីធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។[ccxiii] យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ថវិកាជាតិ (ក្នុងឆ្នាំ២០០០) បានបែងចែកសម្រាប់ប្រព័ន្ធយុត្តិធម៌គឺត្រឹមតែ ០.៣០%[ccxiv] និងការបែងចែកថវិកាជាតិសម្រាប់ក្រសួងយុត្តិធម៌ (ក្នុងឆ្នាំ២០១១) គឺប្រហាក់ប្រហែលនឹង ០.៨២%[ccxv] ដែលមិនខុសគ្នាពីការបែងចែកកាលពីឆ្នាំ២០០០។ ធនាគារអភិវឌ្ឍន៍អាស៊ី បានបញ្ជាក់ថា ការផ្ដល់ប្រាក់បៀវត្សន៍ក្នុងកម្រិតទាប មិនបានធានាឲ្យចៅក្រមមានកម្រិតជីវភាពប្រដំប្រសងនឹងកម្រិតនៃការទទួលខុសត្រូវ និងឋានៈរបស់ចៅក្រមទេ។

### ៤.៣. តើនីតិវិធីតុលាការត្រូវបានធ្វើឡើងដោយមិនលំអៀង និងមិនទទួលឥទ្ធិពលពីមន្ត្រីសាធារណៈ ឬក្រុមហ៊ុនឯកជនដែរឬទេ?

ច្បាប់រដ្ឋធម្មនុញ្ញ អំណាចតុលាការ គឺជាអំណាចឯករាជ្យ ក្នុងការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ[ccxvi] ហើយអំណាចនេះមិនត្រូវបានផ្ដល់ឲ្យស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិឡើយ។[ccxvii] ភាពមិនលំអៀង និងឯករាជភាពរបស់តុលាការត្រូវបានធានាដោយព្រះមហាក្សត្រ តាមរយៈជំនួយពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[ccxviii] ការបកស្រាយថា ការចូលរួមរបស់ក្រសួងយុត្តិធម៌នៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចជាការជ្រៀតជ្រែក[ccxix] ទៅក្នុងឯករាជភាពរបស់តុលាការ ព្រោះក្រសួងយុត្តិធម៌ត្រូវបានផ្ដល់អំណាចដោយច្បាប់ស្ដីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីរៀបចំពង្រាងនូវព្រះរាជក្រិត្យ[7] តែងតាំង តម្លើងឋានន្តរសក្តិ ការផ្ទេរតំណែង ព្យួរ និងការដកហូតដំណែងចៅក្រម និងព្រះរាជអាជ្ញា។[ccxx] ក្រសួងយុត្តិធម៌ដើរតួរនាទីជាលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ដែលបំពេញមុខងារជាជំនួយការដល់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការស៊ើបអង្កេតចំពោះការចោទប្រកាន់លើកំហុសវិន័យរបស់ចៅក្រម ឬព្រះរាជអាជ្ញា។[ccxxi] នៅខែកញ្ញា ឆ្នាំ២០០៩ ការងារដែលហាក់ត្រួតស៊ីគ្នា គឺថា ក្រុមជំនួយការរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានបង្កើតនូវ "សកម្មភាពដាក់ពិន័យប្រកបដោយប្រសិទ្ធិភាពខ្ពស់" ចំពោះការប្រព្រឹត្តខុសឆ្គងរបស់ចៅក្រម និងព្រះរាជអាជ្ញា។[ccxxii] ជាងនេះទៀត ក្រសួងយុត្តិធម៌ក៏ត្រូវបានផ្ដល់អំណាចក្នុងការចេញប្រកាសទាក់ទងនឹងការបោះឆ្នោតជ្រើសរើស ចៅក្រម ៣រូប ជាសមាជិកពេញសិទ្ធិនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ៣រូបទៀត ជាសមាជិកបម្រុង។[ccxxiii] ឧត្តមក្រុមប្រឹក្សានៃ

---

[7] កំណែចំពោះភាសាអង់គ្លេសៈពីSub-Decree ទៅជាRoyal Decree

អង្គចៅក្រម ពុំមានថវិកាស្វយ័តដែលផ្តល់ដោយស្ថាប័ននីតិប្បញ្ញត្តិ ប៉ុន្តែជាថវិកាបានមកថវិការបស់ក្រសួងយុត្តិធម៌។[ccxxiv]

ដោយសារច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា កំពុងស្ថិតនៅក្នុងសេចក្តីព្រាង ដូច្នេះ នៅឆ្នាំ២០០៧ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានដាក់ចេញនូវក្រមសីលធម៌មួយសម្រាប់គ្រប់គ្រងចៅក្រម និងព្រះរាជអាជ្ញា។ ក្រមសីលធម៌នេះ គឺមានលក្ខណៈស្របនឹងបទដ្ឋានអន្តរជាតិអំពីឯករាជភាព និងភាពមិនលំអៀងនៃតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានព្រះមហាក្សត្រជាប្រធាន ប៉ុន្តែព្រះអង្គមិនចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាទេ ដោយប្រទានសិទ្ធិជាប្រធានអង្គប្រជុំដល់ប្រធានព្រឹទ្ធសភា។ ការផ្ទេរសិទ្ធិនេះ ត្រូវបានក្រុមសង្គមស៊ីវិលមើលឃើញថា ជាការរំលោភបំពានលើឯករាជភាពរបស់តុលាការ និងការបែកចែកអំណាច។[ccxxv] នៅក្នុងរបាយការណ៍ថ្មីៗនេះ "ការវិភាគលើអព្យាក្រឹតភាព និងឯករាជភាពរបស់តុលាការ" លោកសាស្ត្រាចារ្យ Surya P. Subedi បានផ្តល់អនុសាសន៍ ៨ ចំណុច[ccxxvi] ដើម្បីពិចារណាទាក់ទងទៅនឹងជំនឿទុកចិត្តរបស់សាធារណជន និងបញ្ហាពាក់ព័ន្ធនឹងតុលាការកម្ពុជា។[ccxxvii]

នៅឆ្នាំ២០០៣ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានធ្វើការវិភាគលើប្រភពពីរ ដែលដាក់សំពាធលើឯករាជភាព និងអព្យាក្រឹតភាពរបស់ចៅក្រម គឺ កត្តាការតែងតាំង និងការដាក់វិន័យ និង កត្តាកង្វះថវិកា - ប្រាក់វិភាជន៍ - សម្ភារៈបរិក្ខា - និងហេដ្ឋារចនាសម្ព័ន្ធតុលាការ។ល។[ccxxviii] ក្នុងឆ្នាំ២០០៩ អង្គការ FIDH, LICADHO, CHRAC និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀត បានចេញសេចក្តីថ្លែងការណ៍រួមមួយ ស្តីពីស្ថានភាពសិទ្ធិមនុស្ស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (UPR សេចក្តីថ្លែងការណ៍រួមលើកទី៣ជូន Human Rights Council) ដែលរិះគន់ធ្ងន់ៗចំពោះឯករាជភាព និងអព្យាក្រឹតភាពរបស់តុលាការ។

### ៤.៤. តើតុលាការបានផ្តល់មេធាវីដល់ជនជាប់ចោទ សាក្សី និងជនរងគ្រោះ? តើមេធាវីប្រកបដោយសមត្ថភាពទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងមានចំនួនគ្រប់គ្រាន់ដែរឬទេ?

បុគ្គលម្នាក់អាចក្លាយជាមេធាវី បន្ទាប់ពីបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលច្បាប់រយៈពេល ២៤ខែ នៅឯមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី ឬត្រូវមានបទពិសោធន៍បំពេញការងារ (បទពិសោធន៍ ២ឆ្នាំ ខាងវិស័យច្បាប់ និងមានបរិញ្ញាបត្រច្បាប់) ឬក៏ទទួលបានបណ្ឌិតច្បាប់។[ccxxix] សមត្ថភាពរបស់មេធាវីជំនួយផ្នែកច្បាប់ គឺជាប្រធានបទមួយ ដែលទាមទារឲ្យមានការវាយតម្លៃជាក់ស្តែង។[ccxxx] ផ្អែកតាមចំនួនតួលេខមេធាវីនៅប្រទេសកម្ពុជាមានចំនួនតិចជាង ៦០០នាក់ក្នុងចំណោមប្រជាជនប្រមាណជាង ១៤លាននាក់។ ទោះបីជា ចំនួនមេធាវីមានការកើនឡើង ក៏ចំនួននេះមានការកើនឡើងដ៏តិចតួច។[ccxxxi] ការវាយតម្លៃមួយរបស់កម្មវិធីនីតិរដ្ឋ បានបញ្ជាក់ថា មានមេធាវីចំនួនតិចតួចប៉ុណ្ណោះ ដែលធ្វើការការពារលើរឿងក្តីព្រហ្មទណ្ឌ។[ccxxxii]

### ៤.៥. តើនីតិវិធីច្បាប់ និងតុលាការធានានូវការផ្តល់សេវាគ្រប់គ្រាន់ ធានាសុវត្ថិភាពដល់ជនជាប់ចោទ ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីយុត្តិធម៌ មុនពេលអំឡុងពេល និងក្រោយពេលដំណើរការរឿងក្តីតុលាការ ដំណើរការរដ្ឋបាល និងដំណើរការដទៃទៀតដែរឬទេ? តើមានការធានាដល់សាធារណជន និងភាគីដែលពាក់ព័ន្ធក្នុងអំឡុងពេល

ដំណើរការនីតិវិធីដែរឬទេ?

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សុវត្ថិភាព និងសន្តិសុខសម្រាប់ជនជាប់ចោទ ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីយុត្តិធម៌ ត្រូវបានការពារយ៉ាងល្អប្រសើរ ប៉ុន្តែសេវាទាំងនេះ ពុំទទួលបានទេនៅតុលាការក្នុងស្រុក។ របាយការណ៍រួម UPR ស្តីពីសិទ្ធិមនុស្ស នៅឆ្នាំ2009 បានបង្ហាញអំពីការគំរាមកំហែងចំពោះសកម្មជនការពារសិទ្ធិមនុស្ស[ccxxxiii] និងសកម្មជនដទៃទៀត។[ccxxxiv] ស្ថិតិនៃការគំរាមកំហែងបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ គឺ ៣៧ករណី ក្នុងឆ្នាំ២០០៦ ៤៦ករណី ក្នុងឆ្នាំ២០០៧ និង ៥២ករណី ក្នុងឆ្នាំ២០០៨។ ករណីសំខាន់មួយ ចៅក្រមមួយរូបត្រូវបានបាញ់សម្លាប់ក្នុងរឿងផលប្រយោជន៍សាធារណៈ។[ccxxxv]

## ខ. កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា អ.វ.ត.ក សម្រាប់ជានីតិរដ្ឋ

### ១. ទិដ្ឋភាពរួម និងប្រតិបត្តិការ

បញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់កម្ពុជា ត្រូវបានព្យាករណ៍ជាមុន នៅពេល អ.វ.ត.ក ត្រូវបានបង្កើត និងមូលហេតុនៃការបង្កើតនេះ។[ccxxxvi] និទណ្ឌភាព និងកង្វះការជួសជុលការសំណង បានធ្វើឲ្យកើនឡើងនូវការមិនពេញចិត្ត និងភាពចងកំហឹងពីជនរងគ្រោះ បើទោះបីជា ការផ្តល់ឱកាសដល់ភាគីជនរងគ្រោះ គឺជាយន្តការស្របច្បាប់មួយក្នុងការទទួលបានយុត្តិធម៌ និងអាចជួយឲ្យពួកគេកាត់បន្ថយនូវការគុំគួន និងអាចជួយផ្សះផ្សាចិត្តក៏ដោយ។

បន្ថែមលើនេះ ការបង្កើតតុលាការកូនកាត់ដែលមានមេធាវី និងចៅក្រម (ទាំងជាតិ និងអន្តរជាតិ) បានបង្កើតជាវេទិកាមួយសម្រាប់ផ្លាស់ប្តូរចំណេះដឹងច្បាប់ ជំនាញ និងបទពិសោធន៍ក្នុងការអនុវត្តន៍ល្អៗ ដោយជួយកសាងសមត្ថភាពជំនាញវិជ្ជាជីវៈច្បាប់ និងជួយពង្រឹងនីតិរដ្ឋនៅប្រទេសកម្ពុជា។

**អ.វ.ត.ក** គឺជាតុលាការព្រហ្មទណ្ឌអន្តរជាតិតែមួយគត់ ដែលកំពុងមានរូបរាងនៅក្នុងតំបន់អាស៊ាននាពេលបច្ចុប្បន្ននេះ និងមានលក្ខណៈពិសេសខុសពីតុលាការដទៃទៀត រួមមាន តុលាការព្រទណ្ឌអន្តរជាតិអតីតប្រទេសយោហ្គោស្លាវី តុលាការព្រទណ្ឌអន្តរជាតិប្រទេសរ៉្វាន់ដា និងតុលាការព្រទណ្ឌអន្តរជាតិប្រទេសសេរ៉ាលេអូន។

ទោះបីជា **អ.វ.ត.ក** ជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា ក៏តុលាការកូនកាត់មួយនេះមានយុត្តាធិការដាច់ដោយឡែក ដោយអនុវត្តទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ហើយអនុញ្ញាតឲ្យជនរងគ្រោះចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមានចៅក្រមជាតិ និងអន្តរជាតិ។ តុលាការសាលាដំបូង មានចៅក្រម ៥រូប (កម្ពុជា ៣រូប និងអន្តរជាតិ ២រូប) និង តុលាការកំពូលមាន ៧រូប (កម្ពុជា ៤រូប និងអន្តរជាតិ ៣រូប)។ រាល់ការសម្រេចចិត្តតម្រូវឲ្យមាន "សម្លេងភាគច្រើនដាច់ខាត" មានន័យថា ត្រូវមាន ៤សម្លេង ក្នុងចំណោម ៥សម្លេង នៅអង្គជំនុំជម្រះសាលាដំបូង។ បុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិ គឺមានគោលបំណងរួមស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ដោយដើរតួយ៉ាងសំខាន់ក្នុងដំណើរការកាត់ទោស និងការពារជនសង្ស័យ។ ទោះបីជា នីតិវិធីកម្ពុជាយកមកអនុវត្តនៅតុលាការនេះក៏ដោយ ប្រសិនបើនីតិវិធីនោះមិនបានកំណត់ទៅលើបញ្ហាជាក់លាក់ណាមួយ ឬបើសិនជាមានសំណួរទាក់ទងនឹងស្តង់ដារអន្តរជាតិ ដូច្នេះមានការណែនាំឲ្យប្រើប្រាស់វិធានអន្តរជាតិ។

យុត្តាធិការកាត់ទោសជនជាប់ចោទស្ថិតក្រោមច្បាប់ជាតិ និងអន្តរជាតិ គឺជាការវិវឌ្ឍន៍ដ៏សំខាន់របស់អង្គជំនុំ

ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ **អ.វ.ត.ក** មានយុត្តាធិការលើបទល្មើសក្នុងស្រុកមួយចំនួន ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ឃាតកម្ម ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា) និងបទល្មើសអន្តរជាតិ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានលើសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ **អ.វ.ត.ក** បានកំណត់អ្នកទទួលខុសត្រូវឧក្រិដ្ឋកម្មតែទៅលើមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។

**អ.វ.ត.ក** បានខិតខំផ្សះផ្សាជាតិដោយមិនកាត់ទោសលើកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ព្រោះយល់ថា ពួកគេពុំមានឆន្ទៈប្រព្រឹត្តអំពើយង់ឃ្នង់ និងមិនជាប់ពាក់ព័ន្ធនឹងគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជា។ បុគ្គលដែលនាំយកមកកាត់ទោស គឺជាបុគ្គលដែលទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម គឺជាយន្តការផ្សះផ្សាមួយដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបដ៏យង់ឃ្នង់នេះ។

**អ.វ.ត.ក** បានសម្រេចសេចក្តីលើកដំបូងនៅ ខែកក្កដា ឆ្នាំ២០១០ ដោយផ្តន្ទាទោសលោក **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តនៅមន្ទីរសន្តិសុខទួលស្លែង។ ការវិនិច្ឆ័យលម្អិតនឹងមានចែងដូចខាងក្រោម។

សំណុំរឿង ០០២ គឺជាដំណើរការកាត់ទោសលើកទី២ ចំពោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិតចំនួន ៤នាក់ ដែលគ្រោងនឹងដំណើរការនៅពាក់កណ្តាលឆ្នាំ២០១១។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ **នួន ជា** - **អៀង សារី** - **ខៀវ សំផន** - និង **អៀង ធីរិទ្ធ** ពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលយើងស្គាល់ថា **នួន ជា** គឺជាអនុលេខាបក្សកុំម្មុយនីស្តកម្ពុជា **អៀង សារី** គឺជារដ្ឋមន្ត្រីការបរទេស **ខៀវ សំផន** គឺជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ និង **អៀង ធីរិទ្ធ** គឺជារដ្ឋមន្ត្រីក្រសួងសង្គម កិច្ច។ ទោះបីជា **អ.វ.ត.ក** បានសម្រេចនូវកិច្ចការជាច្រើនចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ២០០៦ ក៏តុលាការមួយនេះ បានប្រឈមនឹងបញ្ហាជាច្រើន។ តុលាការទទួលរងសំពាធក្នុងការធានាឲ្យឆាប់មានដំណើរការសវនាការ និងស្វែងរកយុត្តិធម៌ឲ្យបានឆាប់រហ័សដោយសារតែភាពជរារបស់ជនជាប់ចោទ។

តុលាការនេះក៏ប្រឈមនឹងបញ្ហាថវិកា ហើយទទួលរងការរិះគន់ និងការចោទប្រកាន់ថា មានអំពើពុករលួយព្រមទាំងស្ថិតក្រោមឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជា។[ccxxxvii] ឧទាហរណ៍ថ្មីៗនេះ មានការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងដំណើរការនីតិវិធីថា **អ.វ.ត.ក** ទទួលរងសម្ពាតពីរដ្ឋាភិបាលកម្ពុជាមិនឲ្យធ្វើការចោទប្រកាន់បន្ថែមហួសពីសំណុំរឿង ០០២។ ទោះបីជាយ៉ាងណា សំណុំរឿង ០០៣ និង ០០៤ បច្ចុប្បន្នស្ថិតនៅក្រោមដំណើរការស៊ើបអង្កេត និងមានការទទួលពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាំងពីដើមខែមេសា ឆ្នាំ២០១១។

## ២. នីតិរដ្ឋ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ទោះបីជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទទួលរងការរិះគន់ និងបញ្ហាលំបាកជាច្រើន ក៏តុលាការនេះបានដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងបង្កើតជាគោលការណ៍មួយសម្រាប់ពង្រឹងនីតិរដ្ឋក្នុងប្រទេស

កម្ពុជា (សូមមើលគោលការណ៍ III ខាងលើ)។ ការដំណើរការជំនុំជម្រះត្រូវធ្វើឡើងដោយមានតម្លាភាព និងជាសាធារណៈ ហើយបើកទូលាយឲ្យមានការចូលរួមពីអ្នកសារព័ត៌មាន និងសង្គមស៊ីវិលនានា។ តុលាការនេះគោរពនូវគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌បទដ្ឋានអន្តរជាតិ ដោយលើកកម្ពស់សិទ្ធិសំខាន់ៗរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ទោសប្រកបដោយយុត្តិធម៌ ស្របតាមគោលការណ៍ទី II ។

**អ.វ.ត.ក** គឺជាតុលាការអន្តរជាតិដំបូង ដែលផ្តល់ឲ្យជនរងគ្រោះចូលរួមដំណើរការនីតិវិធីប្រកបដោយអត្ថន័យ ដែលជាវិភាគទានមួយដល់ការព្យាបាលស្លាកស្នាមអតីតកាល និងនាំមកនូវការផ្សះផ្សាជាតិទាំងមូល។

ដំណើរការរីកចំរើនរបស់ **អ.វ.ត.ក** បានធ្វើឲ្យមានការរំពឹងទុកជាខ្លាំងក្នុងការរៀបចំប្រព័ន្ធយុត្តិធម៌នៅក្នុងតុលាការកម្ពុជា តាមរយៈការលើកកម្ពស់ឲ្យមានតម្លាភាព និងការទទួលខុសត្រូវចំពោះមុខច្បាប់ទាំងក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ ជាងនេះទៀត ធានាថា ដំណើរការនីតិវិធីគឺផ្អែកលើសិទ្ធិ និងយុត្តិធម៌ ដែលនឹងជួយជម្រុញឲ្យមានការលើកកម្ពស់ និងកំណែទម្រង់ច្បាប់នាពេលអនាគត ព្រមទាំងលើកទឹកចិត្តឲ្យតុលាការក្នុងស្រុកដំណើរការកាត់ក្តីឲ្យបានត្រឹមត្រូវ។ ការពិនិត្យមើលសេចក្តីសម្រេច និងការបកស្រាយក្រមព្រហ្មទណ្ឌជាតិនៅ **អ.វ.ត.ក** នឹងផ្តល់ជាជំនួយដល់ចៅក្រមជាតិ និងមេធាវីជាតិ នូវមូលដ្ឋានគ្រឹះក្នុងការពិភាក្សាពីបញ្ហានីតិរដ្ឋនៅក្នុងតុលាការជាតិ។ **អ.វ.ត.ក** ក៏ជួយសម្របសម្រួលក្នុងដំណើរការបង្កើតឯកសារយុត្តិសាស្ត្រច្បាប់អន្តរជាតិ ស្តីពីសិទ្ធិមនុស្សជាភាសាខ្មែរ ដែលងាយស្រួលរកបាននៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។

ក្រៅពីជួយដោះស្រាយកង្វះតម្លាភាព និងកង្វះទំនួលខុសត្រូវក្នុងប្រព័ន្ធច្បាប់កម្ពុជា **អ.វ.ត.ក** ក៏បានបង្កើនសមត្ថភាព និងធនធានមនុស្សខាងវិស័យច្បាប់ផងដែរ។ បញ្ហាប្រឈមដ៏សំខាន់នៅកម្ពុជា គឺកង្វះស្ថាប័នជំនាញ និងមានសមត្ថភាពផ្នែកច្បាប់។ ស្របជាមួយនឹងការពង្រឹងសមត្ថភាពលើវិស័យច្បាប់ ចរិកលក្ខណៈរបស់សាលាក្តីកូនកាត់នេះ ក៏បានផ្តល់នូវបរិយាកាសល្អមួយក្នុងការធានាថា ជំនាញការអនុវត្តន៍ និងចំណេះដឹងពី **អ.វ.ត.ក** នឹងត្រូវផ្ទេរទៅស្ថាប័នក្នុងស្រុកតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការពិភាក្សាតុមូលនានា។ មេធាវីជាតិ ព្រះរាជអាជ្ញាជាតិ និងចៅក្រមជាតិ អាចចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនេះ ព្រមទាំងពាំនាំចំណេះដឹងដែលខ្លួនទទួលបានពី **អ.វ.ត.ក** ទៅតុលាការក្នុងស្រុក។

ចាប់តាំងពី **អ.វ.ត.ក** បង្កើតក្នុងឆ្នាំ២០០៦ ចៅក្រម និងមេធាវីបានពិភាក្សាលើបញ្ហាប្រឈមជាច្រើន រួមមានការឃុំខ្លួនបណ្តោះអាសន្ន ប្រភេទនៃការទទួលខុសត្រូវលើបទព្រហ្មទណ្ឌ បណ្តឹងជិតចិត្តចៅក្រម និងយុត្តាធិការ។ អ្នកច្បាប់នៅ **អ.វ.ត.ក** ងាយទទួលរងនូវបញ្ហាក្រមសីលធម៌ និងនីតិវិធីដែលមានកំណត់ក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ឬច្បាប់ទាំងពីរ។ ដូច្នេះ **អ.វ.ត.ក** ផ្តល់នូវបរិយាកាសដ៏ល្អក្នុងការពង្រឹងអ្នកច្បាប់ ដើម្បីបម្រើការនៅក្នុងស្ថាប័នជាតិ។ **អ.វ.ត.ក** ក៏ផ្តល់ឱកាសដល់និស្សិតខ្មែរចុះធ្វើកម្មសិក្សា និងសិក្សាយល់ដឹងពីការងារតុលាការ ព្រមទាំងអប់រំយុវជនខ្មែរពីការរំលោភសិទ្ធិមនុស្សដែលមនុស្សជំនាន់មុនបានជួបប្រទះ និងឲ្យពួកគេយល់ដឹងពីដំណើរការនីតិវិធីព្រហ្មទណ្ឌដែលជនល្មើសទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះការប្រព្រឹត្តល្មើស ដោយតម្លាភាព និងយុត្តិធម៌។

ទោះបីជា សេចក្តីសម្រេចរបស់ **អ.វ.ត.ក** ធ្វើឡើងក្នុងបរិបទនៃឧក្រិដ្ឋកម្មធំៗ ដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មដទៃទៀត ដោយមិនបានឆ្លុះបញ្ចាំងពីដំណើរការអនុវត្តន៍រឿងក្តីប្រចាំថ្ងៃ ក៏ការបកស្រាយច្បាប់ជាតិទាំងឡាយនឹងបន្ថែមជាការយល់ដឹង និងផ្តល់តម្លៃចំណេះដឹងចាំបាច់ដល់អ្នកច្បាប់

កម្ពុជា នៅពេលដែលពួកគេអនុវត្តច្បាប់ទាំងនេះនៅតុលាការក្នុងស្រុក។ **អ.វ.ត.ក** ក៏ជួយពង្រឹងនូវនីតិរដ្ឋនៅប្រទេសកម្ពុជា ដោយអនុញ្ញាតឲ្យជនរងគ្រោះចូលរួមជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីធានាថា ពួកគេបានយល់ដឹងពីដំណើរការកាត់ក្តី ព្រមទាំងផ្តល់ឲ្យពួកគេនូវសំណងរួមមួយដ៏សមរម្យ។ សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមដំណើរការនីតិវិធីនៅ **អ.វ.ត.ក** គឺមានសារសំខាន់ជាងតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត។

ដោយសារតែដំណើរការប្រព្រឹត្តទៅនៃ **អ.វ.ត.ក** អនុវត្តតាមប្រព័ន្ធច្បាប់កម្ពុជា ដូច្នេះ បទប្បញ្ញត្តិទូទៅពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះ ត្រូវបានយកមកអនុវត្ត។ នៅក្នុងកំឡុងពេលនៃការកាត់ទោស "**ឌុច**" គឺជាតឹងតាំងមួយបង្ហាញថា បទប្បញ្ញត្តិនេះគួរតែធ្វើវិសោធនកម្ម ដើម្បីជម្រុញឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងសវនាការជាពិសេស នៅក្នុងសំណុំរឿង០០២ ការចូលរួមរបស់ជនរងគ្រោះមានចំនួនកើនឡើងខ្លាំង។

ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានសម្តែងនូវការខកចិត្តចំពោះការកាត់ទោស "**ឌុច**"។ ជាក់ស្តែង ការរិតត្បិតតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺបង្ហាញពីតម្រូវការឲ្យមានការយកចិត្តទុកដាក់ពីតុលាការកាន់តែខ្លាំងសម្រាប់រឿងក្តីក្រោយៗ។ ការរៀបចំជនរងគ្រោះ និងជួយឲ្យពួកគេមានការយល់ដឹងកាន់តែច្បាស់អំពីដំណើរការតុលាការ គឺជាតម្រូវការដ៏ចាំបាច់។ ជាងនេះទៀត តុលាការបានបើកទូលាយឲ្យមានការជួយគាំទ្រដល់ជនរងគ្រោះ គឺវិធានការក្រៅប្រព័ន្ធតុលាការ ដែលរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះនៃ **អ.វ.ត.ក**។ ការផ្តល់ឲ្យជនរងគ្រោះនូវឱកាស និងចូលរួមនៅក្នុងដំណើរការយុត្តិធម៌ **អ.វ.ត.ក** បានជួយលើកតម្កើននូវតម្រូវការសង្គម ដែលអាចឲ្យប្រជាជនទទួលយកបាន។

## ៣. សាលក្រមរបស់ អ.វ.ត.ក និងការវិនិច្ឆ័យ

*<u>សាលក្រម "ឌុច"</u>*

អតីតប្រធានមន្ទីរសន្តិសុខទួលស្លែង (ស-២១) **កាំង ហ្គេចអ៊ាវ** ហៅ "**ឌុច**" ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរកម្ពុជាក្នុងឆ្នាំ១៩៩៩ និងបានឃុំខ្លួនក្នុងពន្ធនាគារយោធាដោយគ្មានការកាត់ទោសរហូតបញ្ជូនទៅ **អ.វ.ត.ក** នៅឆ្នាំ២០០៧។ សវនាការជំនុំជម្រះ "**ឌុច**" ចាប់ផ្តើមនៅដើមឆ្នាំ២០០៩ និងបានបញ្ចប់នៅ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងកំឡុងពេលនៃសវនាការ តុលាការបានស្តាប់ចម្លើយ "**ឌុច**" សាក្សី ៣៣នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ២២នាក់ ព្រមទាំងមានការចូលរួមពីសាធារណជនប្រមាណជាង ២៨,០០០នាក់។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ តុលាការបានប្រកាសសាលក្រម ដោយផ្តន្ទាទោស "**ឌុច**" ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ តុលាការបានកាត់ទោស **ឌុច** ឲ្យជាប់ពន្ធនាគារ ៣០ឆ្នាំ (បន្ទាប់ពីកាត់បន្ថយ ៥ឆ្នាំ ដោយសារការ ឃុំខ្លួនដោយខុសច្បាប់នៅតុលាការយោធា)។

"**ឌុច**" បានជាប់ឃុំជាង ១១ឆ្នាំ មុនពេលទទួលបានការផ្តន្ទាទោសនៅ **អ.វ.ត.ក** ដូច្នេះ គាត់នៅទទួលទោសតែ ១៩ឆ្នាំ ទៀតប៉ុណ្ណោះ ដោយហេតុនេះ បណ្តាលឲ្យគ្រប់ភាគីប្តឹងឧទ្ធរណ៍ ទាំងភាគី "**ឌុច**" និង សហព្រះរាជអាជ្ញា ហើយសវនាការសាលាឧទ្ធរណ៍បានដំណើរការនៅ ខែមេសា ឆ្នាំ២០១១។ ក្រុមមេធាវីការពារក្តីរបស់ "**ឌុច**" បានលើកទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍ថា "**ឌុច**" មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ **អ.វ.ត.ក** ព្រោះថា គាត់ពុំមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ដូច្នេះ គាត់គួរត្រូវបានដោះលែង។ ចំណែកឯព្រះរាជអាជ្ញា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងសម្រេចសេចក្តីដោយមានការភាន់ច្រឡំ តួយ៉ាង ការបូកបញ្ចូលបទល្មើស (មនុស្សឃាត និងការធ្វើទារុណ

កម្ម) ឲ្យស្ថិតក្រោមការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងខកខានមិនអនុវត្តតាមសំណើសុំឲ្យដាក់ទោសគុក ៤០ឆ្នាំ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល អាចនឹងប្រកាសនៅ ខែមិថុនា ឆ្នាំ២០១១។

សាលក្រមរបស់ "ឌុច" បានសម្តែងឲ្យឃើញនូវព្រឹត្តិការណ៍ដ៏សំខាន់ក្នុងតុលាការព្រហ្មទណ្ឌកម្ពុជា និងអន្តរជាតិ។ សាលក្រម និងការផ្តន្ទាទោស បានបង្ហាញពីការទទួលស្គាល់ការឃុំខ្លួនដោយខុសច្បាប់ និងបង់សងជម្ងឺចិត្តដោយការកាត់បន្ថយទោស។ ការកាត់បន្ថយទោស "ឌុច" គឺបានឆ្លុះបញ្ចាំងពីការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ជាពិសេស ក្នុងករណីនៃការឃុំខ្លួនពាក់ព័ន្ធនឹងការបណ្តេញចេញពីដីធ្លី។

ដើម្បីឲ្យការកាត់ទោស "ឌុច" មានប្រសិទ្ធិភាពជាវិជ្ជមានដល់នីតិរដ្ឋនៅកម្ពុជា ជាសំខាន់ ត្រូវមានការគាំទ្រពីប្រជាជនកម្ពុជា។ ករណីនេះ អាចធ្វើតាមរយៈការផ្សព្វផ្សាយ និងការពន្យល់ដល់ជនរងគ្រោះឲ្យយល់កាន់តែច្បាស់ អំពីសាលក្រម និងការផ្តន្ទាទោស ដែលអាចជួយឲ្យពួកគេស្ងប់ចិត្ត និងផ្តល់តម្លៃដល់សាលក្រម និងជាវិភាគមួយដល់ការផ្សះផ្សាជាតិ។

សាលក្រមនេះ ក៏អាចជួយបង្កើននូវការគាំទ្រ និងចំណាប់អារម្មណ៍លើ **អ.វ.ត.ក** នៅក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ ៤រូបទៀត ដែលគ្រោងនឹងចាប់ផ្តើមនាពាក់កណ្តាល ឆ្នាំ២០១១។ សាលក្រមផ្តន្ទាទោសនេះ គឺជាជំហានដ៏សំខាន់មួយទាំងកម្រិតជាតិ និងអន្តរជាតិ ដែលជនល្មើសម្នាក់នៃរបបខ្មែរក្រហមបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងសម័យនោះ និងផ្តល់ជាគំរូមួយនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នៅកម្ពុជា។

សាលក្រម "ឌុច" មិនត្រឹមតែចូលរួមវិភាគទានដល់ការកាត់ទោសនៅ **អ.វ.ត.ក** នាពេលអនាគតប៉ុណ្ណោះទេ ក៏ប៉ុន្តែសេចក្តីសម្រេចលើប្បញ្ញត្តិច្បាប់ជាក់លាក់មួយចំនួន ដូចជា ការកំណត់អាជ្ញាយុកាល និងបទប្បញ្ញត្តិផ្តន្ទាទោស អាចឲ្យចៅក្រមជាតិ និងមេធាវីជាតិយកទៅប្រើប្រាស់នៅតុលាការក្នុងស្រុកនាពេលខាងមុខ។

<u>សេចក្តីសម្រេចពាក់ព័ន្ធនឹងការចោទប្រកាន់ពីអំពើពុករលួយ</u>

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ពីអំពើពុករលួយ គឺសំដៅលើចៅក្រមជាតិ ជាហេតុនាំឲ្យមានមន្ទិលសង្ស័យពីភាពស្របច្បាប់នៃដំណើរការនីតិវិធី។ ករណីនេះ ឆ្លុះបញ្ចាំងពីការអនុវត្តន៍ច្បាប់មិនត្រឹមត្រូវនៅក្នុងស្រុក ដោយហេតុថា អំពើស្ងួកប៉ាន់ និងឥទ្ធិពលផ្នែកនយោបាយ បានជ្រៀកជ្រែកយ៉ាងខ្លាំងក្នុងដំណើរការយុត្តិធម៌។

ចំណុចជាវិជ្ជមាននៅ **អ.វ.ត.ក** រួមមាន ដំណើរការនៃការស៊ើបអង្កេត បណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ និងបណ្តឹងសុំដិតចិត្តចៅក្រម។ ការច្រានចោលបណ្តឹងសុំដិតចិត្តចៅក្រម **ន័យ ថុល** ដោយចោទប្រកាន់ពាក់ព័ន្ធនឹងអំពើពុករលួយ អង្គបុរេជំនុំជម្រះបានលើកឡើងថា **អ.វ.ត.ក** គឺជាតុលាការឯករាជ្យ និងមិនជាប់ពាក់ព័ន្ធទៅនឹងតុលាការក្នុងស្រុក។

សេចក្តីថ្លែងការណ៍នេះ បានបញ្ជាក់ពីអព្យាក្រឹតភាពនៃតុលាការ និងការបោះជំហានឆ្ពោះទៅរកការបញ្ចប់និទណ្ឌភាព និងការពង្រឹងនីតិរដ្ឋនៅកម្ពុជា។ ដើម្បីឆ្លើយតបនឹងការចោទប្រកាន់ពីអំពើពុករលួយ **អ.វ.ត.ក** បានផ្តល់

ព័ត៌មានជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយសង្កត់ធ្ងន់លើសមត្ថកិច្ច និងអព្យាក្រឹតភាពរបស់ចៅក្រម។ ចំណែកឯការច្រានចោលបណ្តឹងសុំដិតចិត្តចៅក្រម និល ណុន អង្គជំនុំជម្រះបានបញ្ជាក់ថា ៖

*"នៅពេលមានការចោទប្រកាន់ពីភាពសាកសមរបស់ចៅក្រម គឺតម្រូវឲ្យមានយន្តការផ្សេង ជាជាងការងាកទៅរកយន្តការក្នុងស្រុក ដែលធ្វើឡើងតាមបទដ្ឋានយុត្តិធម៌នៅកម្ពុជា។ អង្គជំនុំជម្រះបានយល់ស្របថា ទោះបីជា ការចោទប្រកាន់មានមូលហេតុត្រឹមត្រូវ និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍន៍សមត្ថភាពអ្នកច្បាប់ ដូច្នេះ នៅតែរក្សាទំនុកចិត្តសាធារណជនចំពោះប្រព័ន្ធយុត្តិធម៌។"* [ccxxxviii]

អង្គជំនុំជម្រះបានកត់សម្គាល់ពីតួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការជួយពង្រឹងនីតិរដ្ឋ គឺថា "**អ.វ.ត.ក** បង្កើតឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពអ្នកច្បាប់កម្ពុជា"។

## ៤. គម្រោងកេរដំណែលសាលាក្តី

ការងាររបស់ **អ.វ.ត.ក** អាចផ្សាភ្ជាប់ពីប្រសិទ្ធភាព និងសច្ចភាពនាពេលអនាគតនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក គឺឆ្លុះបញ្ចាំងតាមរយៈគម្រោង "កេរដំណែល"។ តុលាការបាននឹងកំពុងតែពិចារណាជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក្នុងការបង្កើតឲ្យមានជារូបរាង។ ជាទូទៅ ពាក្យថា "ការកេរដំណែល" សំដៅទៅរក "ការជះឥទ្ធិពលជានិរន្តន៍របស់តុលាការកូនកាត់មួយនេះទៅលើការពង្រឹងនីតិរដ្ឋនៅក្នុងសង្គមមួយ...។ គោលបំណងនៃគម្រោងនេះ គឺធ្វើការបន្តក្រោយការបញ្ចប់អណត្តិរបស់សាលាក្តី"។[ccxxxix]

គម្រោងកេរដំណែលរបស់សាលាក្តី រួមមាន ការផ្សព្វផ្សាយសេចក្តីសម្រេចរបស់សាលាក្តីទៅមន្ត្រីពាក់ព័ន្ធដែលធ្វើការនៅតុលាការក្នុងស្រុក ការផ្តល់នូវវគ្គបណ្តុះបណ្តាលដល់និស្សិតច្បាប់ និងអ្នកមានវិជ្ជាជីវៈច្បាប់ និងការផ្សព្វផ្សាយពីគុណតម្លៃសិទ្ធិមនុស្ស ដែលតុលាការជួបប្រទះ។ ចំពោះសេចក្តីសម្រេច និងការបកស្រាយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ក៏ជួយកសាងសមត្ថភាពរបស់ស្ថាប័នជាតិ ដែលអង្គការជាច្រើនបានបង្កើតវិធីសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលនានា ដើម្បីធានាថា **អ.វ.ត.ក** បានបន្សល់កេរដំណែលនៅកម្ពុជា។ ការពិភាក្សាខាងក្រោម គឺបង្ហាញពីការបង្កើតវិធីសាស្ត្រអនុវត្តន៍ជាក់ស្តែង ក្នុងគោលបំណងចែកចាយនូវកេរដំណែលរបស់ **អ.វ.ត.ក** ទៅក្នុងស្ថាប័នជាតិ (ឧទាហរណ៍ សៀវភៅបង្រៀន និងសៀវភៅពន្យល់នានា)។ ដើម្បីយល់ដឹងពីការជះឥទ្ធិពលរបស់ **អ.វ.ត.ក** ទៅលើនីតិរដ្ឋនៅកម្ពុជា យើងត្រូវសិក្សាពីគម្រោងកេរដំណែល ដែលនឹងរៀបចំបង្កើត ឬកំពុងដំណើរការ។

### ក. បណ្ណសាររបស់ អ.វ.ត.ក ក្នុងការរក្សាទុកឯកសារ និងសេចក្តីសម្រេចនានា

**អ.វ.ត.ក** អាចនឹងក្លាយជាតុលាការគំរូ ប្រសិនបើមានយន្តការផ្ទុកឯកសារ និងសេចក្តីសម្រេចរបស់ **អ.វ.ត.ក** ត្រូវបានផ្សព្វផ្សាយទៅដល់តុលាការកម្ពុជា អ្នកមានជំនាញវិជ្ជាជីវៈច្បាប់ និងប្រជាពលរដ្ឋកម្ពុជា។ ដូចដែលបានលើកឡើងខាងលើ នាពេលបច្ចុប្បន្ន ការទទួលបានព័ត៌មានបែបនេះ គឺមិនទាន់មាននៅកម្ពុជាទេ។[ccxl] **អ.វ.ត.ក** មានមុខងារជា

មូលដ្ឋានមួយក្នុងការបង្កើតចងក្រងឯកសារច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសម្រាប់យុវជនខ្មែរជំនាន់ក្រោយ និងប្រជាជនទូទាំងពិភពលោក។ ស្ថាប័នមួយចំនួនបានផ្លាស់ប្តូរបច្ចុប្បន្នភាពរបស់ខ្លួន ដោយបង្កើតនូវបណ្ណសារ ក្នុងការផ្ទុកនូវយុត្តិសាស្ត្ររបស់ **អ.វ.ត.ក**។

សាលាក្តីទូរនិម្មិត (The Virtual Tribunal "VT") គឺជាបណ្ណសារអេឡិចត្រូនិចមួយ ដែលជាកន្លែងស្រាវជ្រាវជាគេហទំព័រអប់រំ និងជាឧបករណ៍ផ្សព្វផ្សាយជាសាធារណៈសម្រាប់តុលាការព្រហ្មទណ្ឌកម្មអន្តរជាតិ និងតុលាការសិទ្ធិមនុស្សនានា។ គោលបំណងចម្បងរបស់សាលាក្តីទូរនិម្មិត គឺសំដៅជួយអភិរក្សកេរដំណែលរបស់ **អ.វ.ត.ក** ដោយប្រែក្លាយឯកសារច្បាប់នានា ទៅជាឧបករណ៍អប់រំដ៏មានប្រសិទ្ធភាពសម្រាប់អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ។ សាលាក្តីទូរនិម្មិត ក៏ជួយពង្រឹងនីតិរដ្ឋនៅកម្ពុជា ដោយផ្តល់ឲ្យសាធារណជនអាចទទួលបានព័ត៌មាន អំពីសេចក្តីសម្រេចសំខាន់ៗ ដែលមានតម្លៃក្នុងដំណើរការកាត់ក្តី។ សាលាក្តីទូរម្មិត មានគោលបំណងបង្កើតនូវវេទិកាសវនាការអេឡិចត្រូនិច ដែលអាចស្វែងរកឯកសារតស៊ូមតិរបស់សង្គមស៊ីវិល និងកិច្ចសម្ភាសជាខ្សែវីដេអូរជាមួយអ្នកចូលរួមសវនាការដែលផ្តល់យោបល់ផ្ទាល់ខ្លួនពាក់ព័ន្ធនឹងដំណើរការនីតិវិធីរបស់តុលាការ។ ការរចនាផ្សេងៗទៀត អាចធ្វើឲ្យអ្នកប្រើប្រាស់ រួមមាន ជនរងគ្រោះ និងអ្នកសិក្សាស្រាវជ្រាវ អាចស្វែងរកព័ត៌មាន និងប្រភពនៃព័ត៌មានដោយងាយស្រួល។

មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ក៏មានគោលបំណងរក្សាទុកឯកសារ ដែលជាសមិទ្ធផលរបស់ **អ.វ.ត.ក**។ មជ្ឈមណ្ឌលនេះ មានឈ្មោះបោះសម្លេងជាយូរហើយក្នុងការរក្សាទុកឯកសារសំខាន់ៗទាក់ទងនឹងរបបខ្មែរក្រហម រួមមាន ទាំងឯកសារ និងរូបភាព។ នាពេលបច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយឈ្មោះថា "វិទ្យាស្ថានស្លឹករឹត" ដែលមានមុខងារជាមជ្ឈមណ្ឌលឯកសារអចិន្ត្រៃយ៍ រួមបញ្ចូល វិទ្យាស្ថានស្រាវជ្រាវ និងបណ្ណាល័យបណ្តុះបណ្តាល សារមន្ទីរ និងបណ្ណសារសារព័ត៌មាន។[ccxli] ទោះបីជា មជ្ឈមណ្ឌលនេះ មិនផ្តោតសំខាន់តែលើឯកសារច្បាប់របស់ **អ.វ.ត.ក** ក៏ដំណើរការនីតិវិធី និងសម្ទិផលនៃសវនាការនឹងក្លាយជាផ្នែកមួយនៅក្នុងវិទ្យាស្ថាននេះ។

ស្ថាប័នទាំងពីរ ទាំងសាលាក្តីទូរនិម្មិត និងវិទ្យាស្ថានស្លឹករឹត មិនត្រឹមតែជាបណ្ណសារដ្ឋាន ដែលផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងការស្វែងរកឯកសារមានតម្លៃប៉ុណ្ណោះទេ ក៏ប៉ុន្តែបេសកកម្មនៃគម្រោងនិមួយៗមានកម្មវិធីអប់រំដ៏មានប្រសិទ្ធភាព ដើម្បីធានាថា ឯកសាររបស់ **អ.វ.ត.ក** និងសេចក្តីសម្រេចនានាអាចឲ្យអ្នកប្រើប្រាស់យល់ដឹង និងប្រើប្រាស់បាន។

### ខ. ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព

មធ្យោបាយផ្សេងទៀត ដែលសេចក្តីសម្រេច និងការអនុវត្តន៍ល្អៗនៅ **អ.វ.ត.ក** ត្រូវបានរក្សាទុក និងផ្សព្វផ្សាយដល់អ្នកជំនាញវិជ្ជាជីវៈច្បាប់ គឺតាមរយៈការអប់រំ។ នាពេលបច្ចុប្បន្ន អង្គការមួយចំនួនបានផ្តល់ជាវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងវគ្គសិក្សានានា ដើម្បីធានាថា គុណតម្លៃនៃតុលាការមិនត្រូវបានបាត់បង់។

ការផ្តួចផ្តើមរៀបចំកម្មវិធីអប់រំច្បាប់ពាក់ព័ន្ធនឹង **អ.វ.ត.ក** ដែលល្អប្រសើរជាងគេ គឺការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដោយរៀបចំជាកិច្ចពិភាក្សាតុមូល ស្តីពីបញ្ហាច្បាប់ ដែលមានការចូលរួមពីមេធាវីមកពី **អ.វ.ត.ក** និងមេធាវីជាតិនានា រៀបចំជាការទស្សនកិច្ចសិក្សារបស់ចៅក្រមជាតិនៅ **អ.វ.ត.ក** រៀបចំសម្របសម្រួលជាកិច្ចពិភាក្សារវាងអ្នកអនុវត្តន៍ច្បាប់ និងនិស្សិតច្បាប់។ ការិយាល័យឧត្តមស្នងការ

អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ក៏មានបំណងគាំទ្រ និងជួយសម្របសម្រួលនូវការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍របស់ចៅក្រម និងអ្នកអនុវត្តន៍ច្បាប់នៅ **អ.វ.ត.ក** ។

អង្គភាពមួយចំនួននៃ **អ.វ.ត.ក** ក៏បានចូលរួមបន្សល់នូវកេរដំណែលអប់រំ តាមរយៈការផ្តល់ជាវគ្គបណ្តុះបណ្តាលនានា។

ការទទួលស្គាល់ថា ការវិវត្តន៍នៃប្រព័ន្ធច្បាប់ក្នុងស្រុកនឹងមិនត្រឹមតែជួយពង្រឹងសមត្ថភាពមេធាវី តែថែមទាំងបង្កើតនូវឱកាសអប់រំសម្រាប់និស្សិតច្បាប់ និងសិស្សវិទ្យាល័យផងដែរ។ ឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវគ្គបណ្តុះបណ្តាលដល់និស្សិតច្បាប់ ដែលមានរយៈពេលមួយសប្តាហ៍ បន្ទាប់ពី ការផ្សព្វផ្សាយសាលក្រមរបស់ "ឌុច" ដោយពិភាក្សាពីបញ្ហាច្បាប់ជាតិ និងអន្តរជាតិ។ មជ្ឈមណ្ឌលនេះ ក៏មានផែនការ រៀបចំវគ្គបណ្តុះបណ្តាលមួយទៀត នៅពេលចាប់ផ្តើមជំនុំជម្រះក្តីក្នុងសំណុំរឿង០០២។ កម្មវិធីបរិញ្ញាបត្រច្បាប់ជាភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានក្លាយជាដៃគូសហការណ៍ជាមួយ **អ.វ.ត.ក** តាមរយៈការផ្តល់ឱកាសដល់និស្សិតឲ្យធ្វើកម្មសិក្សា និងរៀបចំជាបទឧទ្ទេសនាមនៅសាកលវិទ្យាល័យដោយមេធាវីនៃ **អ.វ.ត.ក** ព្រមទាំងរៀបចំឲ្យមានជាសវនាការគំរូខ្នាតអន្តរជាតិ។

**គ. ការបង្កើតនូវសម្ភារៈអប់រំ**

ក្នុងវិស័យអប់រំ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានចូលរួមវិភាគទានដល់នីតិរដ្ឋ ដោយបង្កើតជាសៀវភៅណែនាំ អំពីក្រមព្រហ្មទណ្ឌកម្ពុជា។ នាពេលបច្ចុប្បន្ន ការបង្កើតសៀវភៅនេះ បានពន្យល់យ៉ាងច្បាស់នូវបញ្ញត្តិទាំងឡាយ ដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយមានសេចក្តីកំណត់ពន្យល់ ការបកស្រាយបទបញ្ញា និងការអនុវត្តន៍របស់ **អ.វ.ត.ក** ។ សៀវភៅនេះ ក៏មានបំណងចង់ជួយសហគមន៍កម្ពុជាឲ្យយល់ដឹងច្បាប់ អាចអនុវត្តន៍ និងអាចអភិវឌ្ឍន៍ខ្លួន ដើម្បីជួយពង្រឹងនីតិរដ្ឋនៅកម្ពុជា។[ccxlii]

## ៥. សេចក្តីសន្និដ្ឋាន

